# ព្រះរស់



វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

WAT KHEMARARATANARAM

# សង្ខេបអត្ថបទ

**១.ព្រះរស់គឺអ្វី?** = *បង្ហាញតួអង្គព្រះរស់, ប្រៀបធៀបសកម្មភាពព្រះរស់នឹងអ្នកវិទ្យាសាស្ត្រ ។*

**២.បរមនាមព្រះរស់** = *អំពីនាមផ្សេង ៗ គ្នា តាមសញ្ញាតិ និងគុណភាពស័ក្កសិទ្ធនៃព្រះរស់ ។*

**៣.ដើមកំណើតព្រះរស់** = *អំពីដើមកំណើតមនុស្ស តាមផ្លូវនិងទ្រឹស្តីវិទ្យាសាស្ត្រ ដែលជាប់ទាក់ទងនឹងដើមកំណើតព្រះរស់, យោបល់អ្នកនិពន្ធវិនិច្ឆ័យពីដើមកំណើតមនុស្ស ។*

**៤.ព្រះរស់សាងមនុស្សលោក** = ការសាង៍មនុស្សលោកគ្រាដំបូង៍ និយាយពីចាប់បដិសន្ធិ ដល់ប្រសូត ។ ការសាង៍មនុស្សលោកគ្រាទី ២ និយាយពីប្រសូតិ ដល់ពេញកំឡោះក្រមុំ ។ ការសាង៍មនុស្សលោកគ្រាទី ៣ និយាយពីពេញកំឡោះក្រមុំ ដល់អវសានជីវិត, មានការរក្សាព្រហ្មចារីរបស់ក្រមុំកំឡោះ តុល្យភាពនៃព្រហ្មចារីក្រមុំកំឡោះ, ហេតុដែលបង្កើតអង្គការនានាក្នុងលោក នឹងការជ្រើសរើសរកមហាបុរស ដើម្បីបរិហារអង្គការនោះ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ព្រមទាំងការរើសរកគូរស្វាមីភរិយា តាមសម័យនិយម នឹងបុរាណនិយម ។

**៥.មនុស្សលោកត្រូវដឹងគុណព្រះរស់ = និយាយអំពី** ប្រភេទនៃការដឹង នឹងមិនដឹងគុណ, ប្រៀបធៀបព្រះរស់ នឹងព្រះនៅឯវត្ត ព្រមទាំងសកម្មភាពគ្រប់យ៉ាងក្នុងគ្រួសារ ។

**៦.លទ្ធផលនៃការដឹងគុណនឹងការមិនដឹងគុណ = និយាយ** អំពីបុណ្យ បាប នរក ស្ថានសួគ៌ក្នុងបច្ចុប្បន្ន ឃើញទាន់ហាន់ភ្នែករស់ ។

WAT KHEMARARATANARAM

# ១ - ព្រះរស់គឺអ្វី ?

បូជានីយបុគ្គល អ្នកសាបព្រោះបណ្ដុះពូជមនុស្ស ឱ្យកើតជាពលរដ្ឋ ពលលោក ក្នុងដែនពិភព ហៅថា "**ព្រះរស់**" គឺ មាតាបិតារបស់បុត្រធីតាទាំងឡាយ ។

ពាក្យថា "**ព្រះរស់**" នេះ ជាពាក្យវប្បធម៌មានចំណាស់មួយ មានអាយុច្រើនសតវត្សរ៍មកហើយ បានកើតឡើងក្នុងអារ្យប្រទេសកម្ពុជាយើងនាសម័យអង្គរ ដែលអារ្យជនខ្មែរសម័យនោះ បានបង្កើតឡើងពីឧត្ដមគតិរបស់ខ្លួន ។

មាតាបិតា បានជាហៅថា "ព្រះរស់[១]" ព្រោះជាព្រះពង្រស់មនុស្សលោក គឺកូនប្រុសស្រី ឱ្យរស់រានមានជីវិតនៅក្នុងលោកនេះ ។

មនុស្សលោកគ្រប់ជាតិសាសន៍ទាំងអស់ សុទ្ធតែម៉ែឪ គឺ

១-ន័យមួយទៀត ពាក្យថា "ព្រះរស់".បុរាណជនលោកប្រៀបធៀបមាតាបិតាដែលមានជីវិតរស់នៅក្នុងផ្ទះ នឹងព្រះពុទ្ធបដិមាករសាងពីថ្មជាដើមនៅក្នុងវត្តដែលគ្មានជីវិត, ទើបហៅមាតាបិតាដែលមានជីវិតនោះថា "ព្រះរស់" ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី **រស់ សារី**
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក **ជ្រុន ចន្ធី**

ព្រះរស់បង្កើត គ្មានវត្ថុស័ក្តសិទ្ធ ព្រះឥន្ទ ព្រះព្រហ្ម ព្រះឥសូរ ព្រះនរាយណ៍ ព្រះម្ចាស់សួគ៌ និងតាបសឥសីណាជប់ ឬបង្កើតបានទាល់តែសោះ ។

ឯអ្នកវិទ្យាសាស្រ្តសម័យបច្ចុប្បន្ន ដែលកំពុងចំរើនផុតថ្នាក់ ចេះធ្វើវិទ្យុទូរទស្សន៍ ទូរស័ព្ទ អាចសន្មតបានថាចេះធ្វើ ភ្នែកទិព្វ ត្រចៀកទិព្វ នឹងចេះធ្វើអាវុធបរមាណូ ធ្វើផ្កាយវិទ្យាសាស្រ្ត ថាសហោះ កាំជ្រួចហោះ ទៅព្រះអាទិត្យ ព្រះចន្ទ ទៅផ្កាយ ដែលជាទ្វីបលោកដទៃបានហើយនោះ ក៏មិនអាចរិះរកតាមក្បួនវិទ្យាសាស្រ្ត បង្កើតមនុស្សលោក ឱ្យកើតដូចជាព្រះរស់បានឡើយ បានត្រឹមតែចេះភ្ញាស់ពងមាន់ពងទាជាដើម ដែលសត្វមាន់ទារាពងឱ្យស្រេចហើយប៉ុណ្ណោះ ។ ជាពិសេសអ្នកវិទ្យាសាស្រ្តទាំងនោះ មានតែបំផ្លាញមនុស្សលោក ដែលព្រះរស់បង្កើត ឱ្យវិនាសទៅវិញ ដោយអាវុធកំណាចរបស់ខ្លួន ។

ព្រោះវិទ្យាសាស្រ្ត គឺវិជ្ជាលៃលកផ្សំធាតុ ដែលកើតឡើង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ដោយគំនិតមនុស្សលោកនេះ អាចបង្កើតបានរបស់គ្រប់បែបតាមផលប្រយោជន៍ធាតុតែម្យ៉ាង, គ្មានមេរៀនអប់រំចិត្តមនុស្សឱ្យលះ លោភៈ ទោសៈ មោហៈ ទេ ។ បើវិជ្ជានេះចំរើនដល់ថ្នាក់ត្រឹមណា ទាសភាព អសន្តិភាព និងសង្គ្រាម ក៏ចំរើនដល់ថ្នាក់ត្រឹមនោះដែរ ។ បើអ្នកវិទ្យាសាស្ត្រ មិនយកវិជ្ជាចិត្តសាស្ត្រខាងព្រះពុទ្ធសាសនាទៅប្រើជាមួយផងទេ, វិទ្យាសាស្ត្រនោះនឹងវិនាសទៅវិញដោយស្វ័យប្រវត្តិ ដូចដើមចេក តែចេញផ្លែចំរើនឡើងៗ ដល់ថ្នាក់ទុំហើយ ត្រូវផ្លែនោះសម្លាប់ខ្លួនវិញ ។

អាស្រ័យហេតុនេះ មនុស្សលោក ពិតជាមានតែតួអង្គព្រះរស់ទេ ដែលអាចបង្កើតបាន, បើគ្មានព្រះរស់ មនុស្សលោកប្រាកដជាគ្មាន ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

# ភាសិត

ទីណាមានមនុស្សភេទប្រុសស្រី
ទីនោះគប្បីសន្មតបុះ
ប្រាកដជាមានអង្គព្រះរស់
ដែលធ្លាប់ហៅឈ្មោះថាម៉ែឪ ។
ទីណាដែលគ្មានព្រះរស់ទេ
ទីនោះទំនេរស្ងាត់ពេកក្លូវ
គ្មានមនុស្សដីទឹកគ្មានគ្រប់ផ្លូវ
ពិភពលោកត្រូវសូន្យគ្រប់យ៉ាង ។

( សុខ ស៊ីវ )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

# ២ -បរមនាមព្រះរស់

បរមនាមព្រះរស់ មានច្រើនអនេកផ្លែកៗ គ្នា រាប់មិនអស់ ជានាមប្រកបដោយវិសាលភាពយ៉ាងទូលាយ លាតសន្ធឹងពេញ ផ្ទៃពិភព សំរាប់មនុស្សលោកហៅគ្រប់សញ្ជាតិ ទោះបីមនុស្ស ស្ថិតនៅក្នុងទីកៀនកោះ ចន្លោះស្មសាន សានូស្ពានញកភ្នំ ទូគិម យ៉ាងណា ក៏សុទ្ធតែចេះហៅ បរមនាមហៅព្រះរស់ គ្រប់ៗ គ្នាៈ

ខ្មែរហៅៈ

មាតា, បិតា, ជននី, ជនក, ម៉ែ, ឪ ឬពុក, ម្តាយ, ឪពុក, អ្នក, ចិក, ម៉ៈ ប៉េ ឬ ប៉ា ។

ចិនហៅៈ

ជិម, ស៊ីម, អាប៊ូៈ, អាអាយ, ឡូវម៉ូវ (ម្តាយ)
ចិ, ចេច, ទា ឬទៀ, អាប៉េ, ឡូវតាវ (ឪពុក)

ចារាំង ហៅៈ

ម៉ាម៉ង់, ម៉ាមែរ, ( ម្តាយ )

ប៉ាប៉ា, ម៉ុងពែរ, ( ឪពុក )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

អង់គ្លេស នឹង អាមេរិក ហៅ:

ម៉ែមមី, ម៉ាធឺ ឬ ម៉ុតធឺ ( ម្ដាយ )

ដែត, ដែតឌី, ភែធី ឬ ធីផា, ហ្វាធឺរ ឬ ហ្វាធឺ ( ឪពុក )

ក្លិង្គ ( ហិណ្ឌី ) ហៅ:

ម៉ាំ, ម៉ាម, ម៉ាតា, ( ម្ដាយ )

ប៉ប , ពិតា, បាបា, បាប៉ុ ( ឪពុក )

ជប៉ុន ហៅ:

អូកាសាន់ ( ម្ដាយ )

អូតាសាន់ ( ឪពុក )

រុស្ស៊ី ហៅ:

ម៉ាត់ធ័, ... ( ម្ដាយ )

អាត់តៀតស័ ....( ឪពុក )

អល្លឺម៉ង់ ហៅ:

ម៉ូតឺ ... ( ម្ដាយ )

ហ្វាតឺ ... ( ឪពុក )

ស្ប៉ាញ៉ុល ហៅ:

ម៉ែរ៉ូ...( ម្ដាយ )

ប៉ែរ៉ូ...( ឪពុក )

ទ្រាវិឌ ហៅ:

ម៉ាអ៊ី ឬ អាម្មា...( ម្ដាយ )

អាប៉ុ ឬ អាពុ...( ឪពុក )

លាវ និង សៀម ហៅ:

ម៉ែ ( ម្ដាយ )

ផ៉ ( ឪពុក )

យួន ហៅ:

ម៉ាំវ, ម៉ាហ៎ ( ម្ដាយ )

ចាំវ, ទាំហ៎ ( ឪពុក ) ។ល។[១]

១-បរមនាមព្រះរស់ មាននៅក្នុងពិភពលោកច្រើនជាអនេក ខ្ញុំពុំអាចស្រាវជ្រាវក្នុងពេលដ៏ខ្លី នាំមកសរសេរក្នុងសៀវភៅនេះ ឱ្យគ្រប់ទាំងអស់បានទេ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

បរមនាមទាំងអស់នេះ ជានាមប្រកបដោយគុណភាពពូកែស័ក្តសិទ្ធិក្នុងលោក ។

ពេលដែលកូនប្រុសស្រី មានអាសន្នទុក្ខព្រួយកើតឡើង តែងនឹកឃើញបរមនាមនេះភ្លាម មុនព្រះនាមដ៏ទៃៗ ទាំងអស់ក្នុងលោក ហើយទំសំបូងសង្រួង ដោយលើកដៃប្រណម្យថាៈ "សូមឱ្យគុណមាតាបិតាជួយកូន បើទឹកដោះមាតាថ្លៃសូមឱ្យកូនបានស្រាកស្រាន្ត ធូរស្បើយ របូតរលូតផុតពីគ្រោះថ្នាក់ . . ." ដូច្នេះជាដើម ។

ក្នុងពេលដែលចិត្តកូនប្រុសស្រី បាននឹកសំបូងសង្រួងដូច្នេះ សេចក្តីទុក្ខព្រួយក៏បានធូរថយទៅខ្លះ មួយពេលមួយស្របក់ ឬបាត់ទៅតែម្តងក៏សឹងមាន ដោយអំណាចព្រហ្មវិហារធម៌របស់មាតាបិតា ដែលធ្លាប់ប្រោះព្រំទៅរកកូន តាំងពីបានបង្កើតមក ។

បរមនាមព្រះរស់ គឺពាក្យថា"មាតាបិតា, ម៉ែឪ, អ្នកពុក, ម៉ះប៉ា . . . " ជាដើមនេះ ជាពាក្យយ៉ាងពិរោះ មោះមុតជាប់ស្ថិតក្នុង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ចិត្តគំនិតកូនប្រុសស្រី ពិរោះលើសពាក្យសំដីទាំងអស់ដែលមានក្នុងលោក, កូនប្រុសស្រីពេញចិត្តចង់តែហៅ ហៅហើយហៅទៀត ហៅគ្មានជិនណាយ ។ ក្នុងមួយឆ្នាំមាន ១២ ខែ, មួយខែមាន ៣០ ថ្ងៃ, មួយថ្ងៃៗ ហៅយ៉ាងញឹកញាប់មិនដឹងជាប៉ុន្មានដង, ហៅមិនចេះឆ្អែតឆ្អន់ ហៅតាំងពីកើតរហូតដល់ចាស់សក់ស្កូវ ក៏នៅតែចង់ហៅ មិនចេះអស់ចំណង់ មិនចេះភ្លេច មិនចេះភាន់ច្រឡំ ចាំយ៉ាងច្បាស់ ចាំប្រាកដរត់មាត់ រហូតដល់ពេលជិតផុតដង្ហើមស្លាប់ ក៏នៅតែរបូតភ្លាត់មាត់ស្រែកហៅទៀត ហៅទាល់តែស្លាប់រឹងថ្គាមហា មាត់មិនរួច ទើបឈប់ហៅៗ ព្រោះកូនប្រុសស្រីទាំងឡាយកើតឡើងកាលណា បានស្ថិតនៅក្នុងគំនរព្រហ្មវិហារធម៌របស់ព្រះរស់ដូចៗគ្នា, ចាប់តាំងពីបើកភ្នែកឃើញពន្លឺព្រះអាទិត្យមក ព្រះរស់ បានទទួលស្គាល់ថាជាកូនសំឡាញ់ទទួលរ៉ាប់រងធ្វើជាទីពឹងពុំនាក់អាស្រ័យរបស់កូនគ្រប់យ៉ាង មុនមនុស្សលោកទាំងអស់, កូនបានទទួលការថ្នាក់ថ្នមបបោសអង្អែល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ហើយមានសេចក្ដីសង្ឃឹម ទុកចិត្តយ៉ាងកក់ក្ដៅចំពោះព្រះរស់ ។

ដូច្នេះ ទើបកូនប្រុសស្រី បានចងចាំបរមនាមព្រះរស់មិនភ្លេចមួយវេលា ទោះជាយូរទៅក្លាយខ្លួនជាជនអកតញ្ញូយ៉ាងណាក៏ដោយ តែជួបពេលមានអាសន្នទុក្ខព្រួយដល់ជីវិត ដែលព្រះរស់បានបង្កើតឱ្យនោះ តែងតែភ័យស្លន់ស្លោភ្លាត់មាត់ ស្រែកអំពាវនាវរកបរមនាមព្រះរស់ថា "ម៉ែឪអើយជួយ!..." ដូច្នេះ មិនខាន ។

ឱ! បរមនាមនេះ ពិតជាពិរោះក្នុងលោកមែន!។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ភាសិត

ពាក្យអ៊ី ៗ មិនស្មើនឹងពាក្យថា
ម៉ែ ឪ ម៉ះ ប៉ា ប៉េ បិ ជិប
ជាពាក្យវិសេសឥតអ្វីផ្ទឹម
ពាក្យមានសង្ឃឹមក្នុងលោកិយ ។
ពាក្យនេះជានាមនៃព្រះរស់
មនុស្សលោកទាំងអស់ទាំងប្រុសស្រី
ហៅតាំងពីតូចទើបចេះស្ដី
ដល់ស្លាប់ដេកដីទើបឈប់ហៅ ។

( *សុង ស៊ីវ* )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី *រស់ សារី*
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ៣- ដើមកំណើតព្រះរស់

ព្រះរស់មានដើមកំណើត ជាមួយនឹងមនុស្សលោក ។
ចុះមនុស្សលោកកើតពីអ្វី?

តាមឯកសារក្នុងផ្លូវសាសនា មាននិយាយផ្សេងៗគ្នា ដូចនាំមកខ្លីៗ ខាងក្រោមនេះ៖

## ព្រាហ្មណ៍សាសនា

តាមឯកសារថាៈ ព្រះបរមេស្វរៈ បណ្តាលឱ្យព្រះព្រហ្មណ៍កើតឡើងក្នុងស៊ុត (ពង) ហើយស៊ុតនោះ បែកជាពីរចំណែក ខាងលើកើតជាមេឃ, ខាងក្រោមកើតជាមនុស្សលោក ។

មួយទៀតថា ព្រះមង្គល, ព្រះមន្ត, ព្រះវេទ ប្រជុំគ្នាបង្កើតជាព្រះឥសូរ, ព្រះឥសូរបង្កើតនាងឧមាភគវតីឡើង, ព្រះឥសូរ និងនាងឧមាភគវតី បង្កើតព្រះនារាយណ៍ និងព្រះព្រហ្មធាតាឡើងទៀត ទើបនាំគ្នាបង្កើតទឹក ដី មេឃ អាកាស មនុស្ស សត្វ ថ្ងៃ ខែ ឆ្នាំ ឡើង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

# គ្រិស្តសាសនា

តាមឯកសារថា ព្រះជេហូវ៉ា បានសាងដីនិងពន្លឺឱ្យមាន យប់ថ្ងៃឡើងក្នុងថ្ងៃចន្ទ, ដល់ថ្ងៃអង្គារសាងទឹកសាងពពក, ថ្ងៃពុធសាងព្រៃឈើ, ថ្ងៃព្រហស្បតិ៍សាងព្រះអាទិត្យព្រះចន្ទនិងផ្កាយ, ថ្ងៃសុក្រសាងសត្វទឹកសត្វស្លាប, ថ្ងៃសៅរ៍សាងសត្វគ្រប់មុខ និងបង្កើតមនុស្សប្រុសម្នាក់ឈ្មោះ "អាដាម" តមកបានដកយកឆ្អឹងជំនីអាដាមមួយ មកសាងជាមនុស្សស្រីម្នាក់ ឈ្មោះ "អេវ៉" ដល់ថ្ងៃអាទិត្យព្រះឈប់សម្រាក ។

# ឥស្លាមសាសនា

តាមឯកសារ មានតំណាលដូចគ្រិស្តសាសនាដែរ ប្លែកតែឈ្មោះព្រះអ្នកសាងគឺ ព្រះខាងព្រះគ្រិស្តឈ្មោះ "ជេហូវ៉ា" ព្រះខាងឥស្លាមសាសនាឈ្មោះ "អល់ឡោះ" ។

# ផ្នែកវិទ្យាសាស្ត្រ

តាមទ្រឹស្តីចង្អុលឡាក់ឋានអំពីការពិសោធន៍ថាៈ គ្រោងឆ្អឹង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

អវយវៈរបស់សត្វ បានផ្លាស់ប្តូរក្លាយៗ មក រហូតដល់បានកើតជាមនុស្ស គឺក្នុងគ្រាដ៏បូងច្រើនលានឆ្នាំមកហើយ ដូចជាសត្វត្រីផ្លាស់អវយវៈក្លាយ ជាសត្វចេះលូនវារមានពស់ជាដើម, តពីនោះមក ពស់ក្លាយជាសត្វទ្វេបាទ ចតុប្បាទ, តមកទៀតសត្វទ្វេបាទចតុប្បាទ ក្លាយជាសត្វស្វាៗ ក៏ក្លាយមកជាមនុស្ស ។

មតិមួយទៀតថា "អ្វីៗក៏ដោយ តែងកើតឡើងតាមធម្មតារបស់លោកធាតុនេះឯង គ្មាននរណា សាងបង្កើតទេ" ។

## ពុទ្ធសាសនា

តាមទ្រឹស្តីផ្នែកព្រះពុទ្ធសាសន៍ថាៈ មនុស្សសត្វទាំងអស់មានកម្មជាអ្នកសាង គឺផ្សំផ្គុំឡើងអំពីរូបធាតុ នឹងអរូបធាតុ ហើយមានកិលេសធំៗ ធ្វើឱ្យកើតច្បាស់ជារូបរាងឡើង, ឯរបស់ដែលគ្មានវិញ្ញាណដូចរុក្ខជាតិជាដើម មានធម្មតាធមិកសាងផ្សំផ្គុំឡើងអំពីររូបធាតុ ចែកទៅតាមគួរដល់ពូជពន្ធុ នឹងកាលៈទេសៈ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# យោបល់អ្នកនិពន្ធ

ដើមកំណើតមនុស្ស តាមព្រាហ្មណ៍សាសនា, គ្រិស្តសាសនា និងឥស្លាមសាសនា ទាំងបីនេះ បើពិនិត្យរកហេតុផលទៅឃើញថា ជារឿងដែលកវីនិពន្ធប្រឌិតតែងឡើងខាងក្រោយផ្សំទៅតាមកាលៈទេសៈ ដែលមានហើយនោះទេ, ព្រោះសាសនាទាំងបីនេះ បានបដិសេធចោលកម្ម ដែលជាហេតុជាពូជហើយទៅយកព្រះ យកទេវតាមកធ្វើជាហេតុជាពូជទៅវិញ ដល់កើតជាផលមកផ្ទុយគ្នាខុសពីពូជស្រឡះគឺ ពូជជាព្រះ ជាទេវតា កើតផលទៅជាមនុស្ស សត្វ ដី ទឹក ភ្លើង ខ្យល់ ឈើព្រៃព្រឹក្សាលតាវល្លិ៍ទៅវិញ ។

តើក្នុងលោកយើងនេះ ដែលមាននរណា ធ្លាប់ឃើញមនុស្សកើតកូនមកជាឈើឬទេ? ឬក៏ដែលឃើញដើមឈើចេញផ្លែមកជាមនុស្សដែរ? ប្រាកដជាមិនដែលឃើញទាល់តែសោះគ្រាន់តែដែលឮខ្លះក្នុងរឿងព្រេង ដូចជារឿងនាងបទុមសុរិយា ជាដើម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ដែលកើតពីផ្កាឈូក ។

ដូច្នេះរឿងកំណើតមនុស្សក្នុងសាសនាទាំងបី ពិតជារឿងព្រេង គឺជាស្នាដៃយ៉ាងឯករបស់កវីនិពន្ធណាម្នាក់ ដែលបានប្រឌិតតែងឡើង ពុំមែនជារឿងពិតទេ ។

បើតាមទ្រឹស្តីខាងពុទ្ធសាសនា នឹងខាងវិទ្យាសាស្ត្រសម័យបច្ចុប្បន្នឃើញសមហេតុផលច្រើន ល្មមជឿថាជារឿងពិតបាន ។

ចុះអ្វីជាដើមកំណើតមនុស្សពិតប្រាកដ?

## ពុទ្ធសាសនាថា:

“សព្វសត្វទាំងអស់ មានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង” ។ ព្រះពុទ្ធដីកានេះ សរុបទាំងកំណើតថ្មី និងកំណើតចាស់ ។

ពាក្យថា កំណើតចាស់គឺ វិញ្ញាណសត្វដែលកើតមានក្នុងលោកយូរហើយ ការកើតស្លាប់ៗ ច្រើនអត្តភាព, ស្លាប់ពីជាតិមួយ ទៅចាប់ជាតិមួយទៀត មានកម្មនាំទៅកើត បានផល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ល្អអាក្រក់សុខទុក្ខទៅតាមកម្មរបស់ខ្លួន ដែលខ្លួនបានធ្វើហើយ ។ ពាក្យថា កំណើតថ្មី គឺវិញ្ញាណថ្មី ដែលទើបតែនឹងកកើតឡើងក្នុងលោកជាបឋម, នេះក៏កើតពីកម្មដែរ ។ ដូចខាងក្រោមនេះ ÷

**ធម្មតានិយម** = សាងបង្កើតថលជជាតិនិងជលជជាតិ[១]

មានឈើ ស្មៅ វល្លិ៍ ព្រលឹត ត្រកួន ជាដើម ។

**កម្ម** = សាងបង្កើតមនុស្សសត្វ ។

ស្របនឹងវិទ្យាសាស្ត្រ ដែលថាអ្វីៗ កើតឡើងតាមធម្មតារបស់លោកធាតុ, តែមិនមែនកើតឯងដោយធម្មជាតិរបស់វាទេ ។

សរសេរត្រឹមប៉ុណ្ណេះ ប្រហែលអ្នកអានស្តាប់ពុំទាន់បានទេ ព្រោះខ្លីពេក សុទ្ធតែជាបរមត្ថផង ។

ដើម្បីងាយយល់ សូមជ្រាបថា ÷

១-ថលជជាតិ: វត្ថុកើតលើគោកមានឈើជាដើម, ជលជជាតិ: វត្ថុកើតក្នុងទឹក ឬលើទឹក មានសារាយ ចក ព្រលិត ត្រកួន កញ្ចែតជាដើម ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ធាតុ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ជារបស់ចាំបាច់សំរាប់លោក គ្មាននរណា សាងបង្កើតទេ ហើយគ្មានបាត់បង់ទៅណាពីក្នុង លោកនេះផង, ទើបមានឈ្មោះតាំងពីព្រេងនាយមកថា "លោកធាតុ "។ ក្នុងធាតុមួយ ៗ មានជីវធាតុល្អិតជាអតិបរមា ៧ ដូចធាតុខ្យល់ មានជីវធាតុ ៧ គឺ ដី, ទឹក, ភ្លើង, ពិណ, ខ្លិន, រស, ឱជា រួមនៅក្នុងខ្យល់នោះ រាប់ទាំងខ្យល់ផង ជាធាតុ ៨ តែយើងមើលដោយភ្នែកធម្មតាមិនឃើញ ញែកចេញពីគ្នាមិនកើត ។ នេះជាធម្មតាធិម, ដល់ធាតុទាំងនេះ ស្របប៉ះទង្គិចផ្សំផ្គុំគ្នា ជាបច្ច័យឱ្យកើតសង្ខារៗ ក៏តាក់តែងធ្វើកើតទៅជានេះជានោះ តាមកាលៈទេសៈ អំពើដែលសង្ខារតាក់តែងធ្វើនោះ ឈ្មោះថាកម្ម (នេះជាបឋមកម្មយ៉ាងល្អិតស្តួចស្តើងមុនដំបូង) ។

ឧទាហរណ៍ៈ ដូចទឹកភ្លៀង ធ្លាក់ចុះពីអាកាសមកដក់នៅដី សង្ខារតាក់តែងយូរៗ ទៅ កើតជាថលជជាតិ ឬជលជជាតិល្អិតៗ មានពិណខៀវអណ្តែតត្រាលើទឹក ឬកកជាប់នៅលើដី, យូរថ្ងៃខែ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ទៅកើតជាចក សារាយ ប្រខ្លបជាដើម ។ ថលជជាតិនិងជលជជាតិទាំងនោះ ខ្លះមានវិញ្ញាណ កកើតឡើងយ៉ាងស្ដួចស្ដើងជាអតិបរមា ដូចដើមកញ្ឆែតឬប្រខ្លប បើមានអ្វីទៅប៉ះវាចេះគេចចេះក្រាប ឈប់ប៉ះវាងើបឡើងវិញ, ខ្លះចេះដេកយប់ថ្ងៃក្រោក ដូចដើមអំពិលជាដើម, ដល់ឈើនោះស្លាប់ទៅចំហាយធាតុនោះ ផ្សាយទៅប៉ះនឹងធាតុដទៃទៀត ដែលមានសមុដ្ឋានស្របគ្នា ក៏មានវឌ្ឍនភាព អាចកកើតទៅជាសត្វមានវិញ្ញាណមធ្យមបាន ដូចកណ្ដូបកើតពីស្លឹកគគ ស្លឹកស្មៅ ដែលមានស្លាបជាស្លឹកឈើស្រស់ៗ ។ ក្នុងពេលនោះនាមរូបថ្មីក៏មានប្រាកដឡើងគឺ បើសត្វនោះមានសណ្ឋានរូបរាងជាកណ្ដូប ក៏ឈ្មោះកណ្ដូបទៅ។ ឯចំហាយធាតុនោះកាលបើទៅប៉ះនឹងធាតុដទៃៗ ដែលមានសមុដ្ឋានត្រូវគ្នា អាចកើតទៅជាសត្វផ្សេងៗច្រើនបែបទៀត ដូចជាដង្កូវទឹក, ខ្ទុត, ដូង នឹងចៃល្អិតៗកើតនៅស្លឹកឈើជាដើម ដែលធ្លាប់ឃើញកើតនៅស្លឹកស្ពៃ ក្នុងទឹក ក្នុងគល់ឈើពុក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ក្នុងគ្រាប់រុក្ខជាតិផ្សេងៗ មានគ្រាប់ពោត សណ្តែកជាដើម ។

កាលបើវិញ្ញាណមធ្យមមានហើយ កម្មជាមធ្យមក៏មានដែរ, វិញ្ញាណនិងកម្មដោយ មានធាតុជាប្រភព មានសង្ខារជាជាងរចនា អកុសលប្រាកដពេញទី ទំរាំបានអត្តភាពជាមនុស្សនេះយូរយារ ណាស់រាប់មិនបានស្មានមិនត្រូវ បានកើតជាមនុស្សហើយក៏មិន ទៀងទាត់វិលវល់ត្រឡប់កើតជាសត្វវិញតាមកម្មរបស់ខ្លួន ។

សង្ខារដែលមានធម្មតាធិមជាប្រភព ចេះតែតាក់តែងកើតតៗ គ្នាដូច្នេះ សមនឹងព្រះពុទ្ធដីកាថាៈ "អវិជ្ជា បច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ" ។ បេ ។

សង្ខារ[១] ទាំងឡាយកើតមាន ព្រោះអវិជ្ជា[២] ជា

---

១-សង្ខារមានច្រើនផ្នែក ក្នុងទីនេះសំដៅយក អនុបាទិន្នក សង្ខារ "មគឺការ តាក់តែងបង្កើតនូវអ្វីៗ ដែលគ្មានវិញ្ញាណ ។

២-អវិជ្ជា គឺ ការមិនដឹងទុក្ខ, មិនដឹងហេតុកើតទុក្ខ, មិនដឹងធិមរលត់ទុក្ខ មិនដឹងសេចក្តី ប្រតិបត្តិដើម្បីរលត់ទុក្ខ គឺមោហៈធិម ។ នេះតាមផ្នែកមួយក្នុងទ្រឹស្តីពុទ្ធសាសនាខាងអរូបនិយម ។ បើខាងរូបនិយមវិញ ដូចអវិជ្ជាក្នុងទីនេះ គឺតួធាតុ ដី ទឹក ភ្លើង ខ្យល់ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

បច្ច័យ, វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ, នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ" ។ល។

ម្យ៉ាងទៀតសូមកុំច្រឡំ ក្នុងគម្ពីរទីឃនិកាយសុត្តន្តបិដក និងគម្ពីរវិសុទ្ធមគ្គ[1] ដែលនិយាយពីភ្លើងឆេះកប្បហើយ កកើតលោកជាថ្មីទៀតនោះ មិនមែននិយាយចំពោះកំណើតមនុស្សដើមបំផុតដែលទើបកកើតថ្មីៗ នោះទេ គឺនិយាយពីលោកធាតុមួយសែនកោដិដែលដល់កំណត់ត្រូវវិនាសទៅវិញ ហើយលោកសង្ខារតាក់តែងលោកធាតុថ្មីទៀត, ពួកមនុស្សសត្វនៅក្នុងលោកធាតុចាស់ដែលត្រូវវិនាសនោះ ខ្លះទៅកើតឋានព្រហ្មណ៍ ខ្លះទៅកើតលោកធាតុដទៃៗទៀតតាមយថាកម្ម, ដល់មានលោកធាតុថ្មីកើតឡើង មនុស្សសត្វខ្លះក៏មកកើតតាមកម្មរបស់ខ្លួនដែរ។ ព្រោះក្នុងផ្ទៃអាកាសល្ហល្ហេវនេះ មានលោកធាតុ មួយសែនកោដិៗ

---

១-គម្ពីរត្រៃភូមិលោកវិនិច្ឆ័យ គម្ពីរលោកទីប នឹងគម្ពីរលោកវិត្ថារ ក៏មាននិយាយស្របនឹងពុទ្ធសាសនាច្រើនដែរ, តែអ្នកនិពន្ធគម្ពីរនោះ បាននិពន្ធលាយបំរុះទាំងសាសនាព្រាហ្មណ៍ផង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

រាប់មិនអស់មានព្រះពុទ្ធត្រាស់បរិនិព្វានរាល់ៗថ្ងៃ។ ហេតុនេះ បានជាមានពាក្យបុរាណថា “ព្រះពុទ្ធអម្បាលខ្សាច់” ។

ឯកំណើតមនុស្សសត្វដែលកម្មជាបឋមបង្កើតឡើងថ្មី ក៏ចេះតែកើតថែមក្នុងមួយថ្ងៃៗ រាប់មិនអស់ ទើបចេះតែមានមនុស្សសត្វពាសពេញលោក ទោះទៅនិព្វានច្រើនយ៉ាងណាក៏មិនចេះអស់ ។

ដូចរៀបរាប់មកដោយសង្ខេបនេះ មនុស្សលោកពិតជាកើតពីកម្ម, ព្រះរស់ក៏កើតពីកម្ម ទើបបង្កើតមនុស្សលោក តៗមក ពាសពេញផ្ទៃលោកដូចសព្វថ្ងៃនេះ។

( ចប់យោបល់អ្នកគិតគូ ក្នុងរឿងកំណើតមនុស្ស )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

# ភាសិត

មនុស្សលោកមានកម្មជាពូជពន្ធុ
មិនមែនវេទមន្តព្រះអាល្ល៉ាហ៍
ព្រះព្រហ្ម ឥសូរ ជេហូវ៉ា
សេពមន្តគាថាបង្កើតបាន ។
កំណើតមនុស្សពិតកើតពីកម្ម
ផ្សំធាតុទាំងប្រាំបីកើតប្រាណ
ធម្មតាតាក់តែងតាមលំអាន
កើតបានជាឈើព្រៃព្រឹក្សា ។
( *សុង ស៊ីវ* )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ៤- ព្រះរស់សាងមនុស្សលោក

ព្រះរស់គឺមាតាបិតា ពុំមែនគ្រាន់តែចេះបង្កើតមនុស្សលោកឱ្យកើតយ៉ាងវិសេស ដែលគ្មានវត្ថុស័ក្តិសិទ្ធិណា អាចបង្កើតបាននោះប៉ុណ្ណោះទេ, លោកបុិនប្រសព្វយ៉ាងឯក ខាងការចិញ្ចឹមរក្សាថ្នាក់ថ្នមលើកទឹកចិត្ត អប់រំ ទំនុកបំរុង ដែលសុទ្ធតែប្រកបដោយព្រហ្មវិហារធម៌, ទោះបីមានពួកអ្នកជំនាញខាងការចិញ្ចឹមបីបាច់រក្សាយ៉ាងណា ក៏មិនអាចធ្វើជំនួស ឱ្យបានប្រសើរគ្រប់យ៉ាងដូចព្រះរស់ដែរ បើទុកជាជួលដោយវត្ថុមានតម្លៃយ៉ាងណា ក៏អ្នកស៊ីឈ្នួល ធ្វើឱ្យល្អវិសេស, ដូចព្រះរស់មិនបានទាល់តែសោះ ព្រោះមិនមែនជាតួអង្គព្រះរស់ ។

## ការសាងមនុស្សលោកគ្រាដំបូង.

( ពីចាប់បដិសន្ធិ ដល់ប្រសូតិ )

មូលហេតុដែលមនុស្សលោកចាប់បដិសន្ធិ, តាមទ្រឹស្តីពុទ្ធសាសនាថា មាន៣យ៉ាងគឺៈ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

-២៨-

១- មាតាបិតាបានរួមរស់មេត្រីជាមួយគ្នា,

២- មាតាមានឧតុសម័យល្អ គឺទើបនឹងមានផ្កាវដូវហើយ,

៣- មានមនុស្សបំរុងមកកើត ។

បើខ្វះហេតុណាមួយមិនអាចកើតបាន ។

ផ្នែកវិទ្យាសាស្ត្របញ្ជាក់ថា "ទីបំផុតនៃការរួមរស់មេត្រី មានជាតិ ស្ពែរម៉ាតូហ្សូអ៊ីត (spermatozoide) របស់បិតា ចេញមកជាច្រើនដំណក់ ក្នុងមួយដំណក់ៗ មានមេក្រូប គឺមេជាតិស្ពែរម៉ាតូហ្សូអ៊ីត រាប់លាន ច្រើនឥតគណនា, បើជាតិនោះ ចូលទៅក្នុងកន្លែងវិសេសមួយរបស់មាតា ហៅអូវីល (Ovul) បានតែមួយ ឬពីរបីមេ យ៉ាងច្រើន ក្នុងមេជាតិមួយកើតបានកំណើតមួយ ហើយអូវីលនោះត្រូវបិទដោយស្វយ័ត មិនឱ្យចូលទៅទៀតបាន ដើម្បីផ្សំគ្នានឹងធាតុមាតា បង្កើតមនុស្សឡើង ។

ចាប់តាំងពីមនុស្សលោកមកជ្រកនៅក្នុងផ្ទៃពេលណា ព្រះរស់គឺមាតាបិតា មានសេចក្តីត្រេកអរប្រកបដោយការព្រួយបារម្ភ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

លាយឡំគ្នា ប្លែកជាងសេចក្ដីត្រេកអរចំពោះអ្វីៗ ដែលមាននៅក្នុងលោក, មានបំណងតែមួយស្របគ្នា គឺចង់ឱ្យកូនរស់ប្រកបដោយសុខភាពបរិបូណ៌ ប្រកបដោយប្រាជ្ញាស្មារតី ដោយយសស័ក្តិ ប្រកបដោយទ្រព្យសម្បត្តិ ចង់ឱ្យរស់យ៉ាងរាប់រយឆ្នាំ រស់ដល់ទំពារបាយរបូតខាំពោតរបេះ ត្បាលចេះចេញផ្លែ អង្រែចេញស្លឹក, បើប្រសិនជាមនុស្សលោកអាចរស់នៅបានស្មើនឹងផែនដី មាតាបិតាក៏បួងសួងប្រតិស្ឋអធិស្ឋាន ឱ្យកូនរស់នៅស្មើនឹងអាយុផែនដីដែរ ។ នេះជាទំហំហឫទ័យមាតាបិតាដែលប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនប្រុសស្រី ។

មាតាបិតាមិនគ្រាន់តែចង់ឱ្យកូនរស់ៗ ប៉ុណ្ណោះទេ ខំថែរក្សាផ្គត់ផ្គង់កូនគ្រប់មធ្យោបាយទាំងអស់ មានចលនារស់រវើកគ្រប់ឥរិយាបថទាំង៤ គឺ ដេក, ដើរ, ឈរ, អង្គុយ ។

## ផ្នែកមាតា

ពេលដេក = មាតាមិនហ៊ានប្រះដេកខ្លាំង ដេកផ្កាប់មុខ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ឬដេកសង្កត់កល់អ្វីៗទេ ក្រែងមិនបានសុខស្រួលដល់កូនក្នុងផ្ទៃ ឬក្រែងមានអន្តរាយដល់ជីវិតកូន, ដេកធាប់ក្រោក ដេកមិនពេញភ្នែក មិនហ៊ានទម្រន់ទៅតាមការងោកងុក, ក្រែងមិនស្រួលដល់ពេលប្រសូតិ ។ មាតាមិនបានដេកពេញភ្នែក ដេកស្កប់ស្កល់ស្រួល ដូចកាលពីក្រមុំ ឬពុំទាន់មានគភ៌នោះឡើយ ។

ពេលដើរ = មាតាមិនហ៊ានដើរខ្លាំងឱ្យពេញទម្លាប់ជើងទេ, ដើរប្រុងប្រយ័ត្នថ្នមៗ ក្រែងភ្លាត់ជើងដួលនាំឱ្យមានការភិតភ័យដល់កូនក្នុងផ្ទៃ ឬក្រែងមានអន្តរាយដល់ជីវិតកូន ទោះបីមានហេតុគួរភ័យខ្លាច ក៏មាតាមិនហ៊ានស្ទុះរត់ស្ទូះទ្រាំដើរដោយប្រុងប្រយ័ត្ន, មិនហ៊ានដើរឡើងទីខ្ពស់ពេក, មិនហ៊ានឡើងដើមឈើ, មិនហ៊ានឡើងនឹងចុះច្រាំងចោតជាដើម ។

ពេលឈរ = មាតាមិនហ៊ានឈរដូចកាលពីក្រមុំ ឬមិនទាន់មានគភ៌នោះទេ ឈរដោយប្រុងប្រយ័ត្ន មិនហ៊ានឈរច្រងេង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ច្រង៉ាង ឈរបង់ជំទាញ ឈរយូរទេ ក្រែងនាំមានហេតុមិនសុខស្រួលដល់កូនក្នុងផ្ទៃ ឬ មានហេតុអន្តរាយដល់ជីវិតកូន ។

ពេលអង្គុយ = មាតាមិនហ៊ានអង្គុយខ្លាំង អង្គុយយូរ អង្គុយច្រហោង ឬ អង្គុយទ្រេតផ្អៀងផ្អែកទៅលើវត្ថុអ្វីៗ ដែលរឹងទេ ក្រែងមិនបានសុខស្រួលដល់កូនក្នុងផ្ទៃ ឬក្រែងមានហេតុឱ្យអន្តរាយដល់ជីវិតកូន ។

មិនគ្រាន់តែខំរក្សាថ្នាក់ថ្នម ដោយឥរិយាបថទាំង៤នេះទេ មាតាមិនហ៊ានបរិភោគចំណីអាហារ ដែលមានរសជូរ ចត់ ល្វីង ហឹរប្រៃពេក នឹងក្តៅពេក ត្រជាក់ពេកថែមទៀត ខ្លាចក្រែងកូនក្នុងផ្ទៃមិនបានសុខស្រួល ឬ បណ្តាលឱ្យស្រុតរលូតខូចបាត់បង់ជីវិតកូន ទោះបីមាតាចង់បរិភោគយ៉ាងណា ក៏ស៊ូទ្រាំអត់ដរាបដល់ស្រក់ទឹកមាត់ ហើយបែរជាខំលេប ផឹក ចាក់ ថ្នាំដែលមាតាមិនធ្លាប់លេប ផឹក ចាក់ តាំងពីកើតមក ។

មាតាតស៊ូក្នុងការថែរក្សាយ៉ាងនេះ អស់ថេរវេលា១០ខែគត់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

សេចក្ដីទុក្ខវេទនាចេះតែធ្ងន់ឡើងៗ ដរាបដល់ថ្ងៃប្រសូតិ ។

ក្នុងពេលជិតថ្ងៃប្រសូតិនោះ មាតាពោរពេញទៅដោយទុក្ខវេទនាក្រៃលែង ដរាបដល់ថ្លស់ទឹកមុខក្រៀមស្លេកស្លាំងស្រងូតស្រងាត់ ព្រោះទុក្ខព្រួយច្រើនយ៉ាងៈ ១-ព្រួយក្រែងកូនមិនបានរស់រានមានជីវិតនៅក្នុងលោក, ២-ព្រួយក្រែងខ្លួនគ្មានជីវិតរស់នៅបានថែរក្សាកូន ។

ពេលប្រសូតិ ជីវិតមាតាគ្មានតម្លៃទេ ស្ថិតនៅក្នុងអំណាចមច្ចុរាជអស់ទៅហើយ រូបកាយមាតាជាចំណីរបស់ព្យាធិ មានតែការឈឺចុកចាប់យ៉ាងខ្លោចផ្សា ហាក់ដូចជាគេកាត់កាប់ចិញ្ច្រាំផ្ទៃខ្ទេចខ្ទីជាកំណាត់តូចធំ ជួនកាលដល់សន្លប់ទើបប្រសូតិរួចក៏មាន ។ នេះហើយជាគ្រោះដោតគ្រោះដាំយ៉ាងកាចសាហាវប្រចាំមាតាគ្រប់រូប ដែលពាក្យចាស់ថា ឆ្លងទន្លេ ។ ទោះបីរងទុក្ខវេទនាយ៉ាងខ្លោចផ្សាដូច្នេះក៏ដោយ មាតាគ្មានតូចចិត្ត ឬ អាក់អន់ចិត្តចំពោះកូនទេ ពេញចិត្តទទួលឥតប្រកែកដើម្បីកូន, គ្រាន់តែ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ឮសម្លេងថ្ងូរយំរ៉ា! ឡើងកាលណា ហាក់ដូចជាបាត់ឈឺចាប់អស់រលីង មាតាដែលកំពុងស្ថិតស្រពោន បែរជាស្រស់ញញឹមសួរគេឯងភ្លាមថា កូនខ្ញុំប្រុសឬស្រី?, មាតាត្រេកអរណាស់ហាក់ដូចជាបានចាប់កំណើតថ្មីឲ្យដ៏ឋានសួគ៌ ដោយបានពុះពារឆ្លងរួចផុតគ្រោះថ្នាក់ ជាពិសេសត្រេកអរចំពោះកូន ដែលបានឃើញពន្លឺព្រះអាទិត្យ បានកើតជាមនុស្សលោកហើយ ។

## ផ្នែកបិតា

ព្រះរស់គឺបិតា តាំងពីភរិយាមានគភ៌មក មានសេចក្តីត្រេកអរ លាយឡំដោយការព្រួយបារម្ភ យ៉ាងធ្ងន់ត្រួតៗ គ្នាគឺ៖ ១-ព្រួយក្រែងទារកក្នុងគភ៌ភរិយា ពុំបានបរិបូណ៌ដោយសុខភាព មិនបានរស់រានមានជីវិតបានឃើញពន្លឺព្រះអាទិត្យ, ២-ព្រួយក្រែងភរិយាមានគ្រោះថ្នាក់ ដែលបណ្តាលមកពីមានគភ៌ ឬ មានគ្រោះថ្នាក់បាត់បង់ជីវិតក្នុងពេលឆ្លងទន្លេ, ៣-ព្រួយក្រែងខ្លួនមានអន្តរាយផ្សេងៗ រកទ្រព្យសម្បត្តិចិញ្ចឹមកូនប្រពន្ធមិនបាន ឬ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មានគ្រោះថ្នាក់ដល់បាត់បង់ជីវិត នាំឱ្យកំព្រាកូនប្រពន្ធ ។

បិតាទទួលរ៉ាប់រងភារៈទាំងអស់ក្នុងគ្រួសារ នៅពេលដែលភរិយាមានគភ៌រហូតដល់ប្រសូតិហើយពីរបីខែ បិតាទទួលកិច្ចការមេផ្ទះទាំងអស់ថែមទៀត ការណាដែលធ្វើមិនកើត មិនធ្លាប់ធ្វើ ចំណាយធនធានជូលគេឱ្យធ្វើជំនួស ឬ ក៏ពឹងពាក់បងប្អូនញាតិសណ្ដានឱ្យជួយធ្វើ, បិតាប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីកូននឹងភរិយា គឺខំរកទ្រព្យសម្បត្តិបំពេញថវិកាគ្រួសារផង ថែរក្សាភរិយាផង ថែរក្សាកូន មើលថែទាំរបស់ទ្រព្យក្នុងផ្ទះនឹងក្រៅផ្ទះផង នឿយលំបាកគ្រប់ឥរិយាបទទាំងបួន ដេកមិនពេញភ្នែក ដើរ ឈរ អង្គុយមិនបានស្រួល ដូចកាលពីកំឡោះ ឬ កាលភរិយាមិនទាន់មានគភ៌នោះឡើយ, រឹតតែទុក្ខព្រួយថែមទៀត បើភរិយាឈឺ ឬ កូនឈឺ បិតាទទួលការឈឺចាប់នោះ ជាមួយភរិយាផង ជាមួយកូនផង ទេមួយជាពីរជាបី កំពុងតែទុក្ខព្រួយយ៉ាងនេះក៏ដោយ បិតានៅតែខំឆ្លៀតឱកាសរកទ្រព្យសម្បត្តិ សំរាប់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ស្បៀងអាហារ សំលៀកបំពាក់ នឹងថ្នាំកែរោគថែមទៀត ។

នេះជាទុក្ករកម្មរបស់បិតា ដែលអ្នកដទៃមិនមែនបិតា ធ្វើតាមមិនកើត ។

បិតាមានភារៈធ្ងន់បំផុត ខាងការគ្រប់គ្រងរក្សាទូទៅក្នុងគ្រួសារ, ឯមាតាមានភារៈធ្ងន់បំផុត ខាងការគ្រប់គ្រងរក្សាបុត្រធីតាផ្ទាល់ខ្លួន ។ ដូច្នេះមាតាបិតា មានគុណចំពោះបុត្រធីតាស្មើគ្នា គ្មានលើសខ្វះ ។

តាមទ្រឹស្តីពុទ្ធសាសនាថា "កូនប្រុសស្រីគួរលើកបិតាដាក់លើស្មាឆ្វេង លើកមាតាដាក់លើស្មាស្តាំ" ព្រោះមាតាមានភារៈធ្ងន់ខាងការថែរក្សាកូនប្រុសស្រីផ្ទាល់ខ្លួនជាងបិតា, ប៉ុន្តែបិតាមានមានភារៈធ្ងន់ខាងការគ្រប់គ្រងគ្រួសារផ្ទាល់ខ្លួនជាងមាតាដែរ ។

បើមិនមានមាតា បុត្រធីតាក៏គ្មាន, បើមិនមានបិតា បុត្រ0ធីតាក៏គ្មានដែរ ។

ទោះបីព្រះរស់គឺមាតាបិតា ខំថែរក្សាការពារយ៉ាងហ្មត់ចត់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

អស់ពីចិត្តពីថ្លើមដែលសុទ្ធតែប្រកបដោយព្រហ្មវិហារធម៌ យ៉ាងនេះក៏ដោយ នៅតែមានការវិនាសអន្តរាយជីវិតមាតា និងទារកខ្លះៗជាធម្មតា, ជួនកាលទារកទើបតែមកចាប់បដិសន្ធិបានបីបួនខែស្លាប់ក្នុងផ្ទៃទៅក៏មាន ខ្លះដល់ប្រសូតិមកស្លាប់ក៏មាន ខ្លះមាតាស្លាប់ទាំងកូនក្នុងផ្ទៃក៏មាន ខ្លះប្រសូតិមកមាតាស្លាប់ទារករស់ក៏មាន ខ្លះទៀតក្នុងពេលប្រសូតិ ស្លាប់ទាំងពីរនាក់ម្តាយនិងកូនក៏មាន សុទ្ធតែជាគ្រោះថ្នាក់ដែលចៀសវាងមិនផុត ព្រោះជីវិតរបស់សត្វលោកមិនទៀង គ្មានកាលបរិច្ឆេទពិតប្រាកដ ។

អាស្រ័យហេតុនេះ ទើបព្រះរស់នាំគ្នាបង្កើតអង្គការសុខភាពឡើងក្នុងលោក ខំត្រិះរិះរាវរកសមុដ្ឋានរោគ ដែលជាឧបសគ្គក្នុងដំណើរជីវិតមនុស្ស និងថ្នាំឱសថសំរាប់បំបាត់រោគ កើតបានជាក្បួនវេជ្ជសាស្ត្រឡើង តាមកាលៈទេសៈ ដរាបមកដល់សម័យបរមាណូនេះ ដើម្បីសាងលោកឱ្យបានស័ក្កសិទ្ធ ប្រកបដោយសុខភាព ប្រាសចាកការវិនាសអន្តរាយជីវិតមនុស្ស ចាប់តាំង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ពីបដិសន្ធិក្នុងគភ៌ជាដំបូងមក ។

ប្រទេសមួយៗក្នុងលោក សុទ្ធតែមានក្រសួងសុខាភិបាល ជាចាំបាច់, ក្រសួងនេះចែកជាច្រើនផ្នែក មានផ្នែកមន្ទីរពេទ្យធំបជាដើម សំរាប់ពិនិត្យថែរក្សាគភ៌ រហូតដល់ប្រសូត្រហើយនឹងរក្សាព្យាបាលទារក...។

ដូច្នេះក្រសួងសុខាភិបាលនេះ ពិតជាស្នាដៃមួយរបស់ព្រះរស់ បានបង្កើតឡើងដើម្បីសាងលោក ។

## ការសាងមនុស្សលោកគ្រាទី ២

( ពីប្រសូតិ ដល់ពេញកម្លោះក្រមុំ )

ព្រះរស់គឺមាតាបិតា ចាប់តាំងពីប្រសូតិបុត្រធីតាហើយ, បានស្រាកស្រាន្តការព្រួយបារម្ភខ្លះ ប៉ុន្តែមានករណីយកិច្ចចំពោះកូនរឹតតែច្រើនឡើងគ្មានទីបំផុត ។

មាតាទទួលការឈឺចាប់ ដែលគ្រាំគ្រាក្នុងពេលប្រសូតិវេលាជាច្រើនថ្ងៃ ទំទ្រាំអាំងភ្លើង ផឹកថ្នាំប្រៃល្វីងចត់ តមក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្ធី

អាហារខ្លាចទាស់ ឬខំទ្រាំនឹងមុខម្ហូបដែលពេទ្យចាក់ ទ្រាំអត់នឹងអំណាចថ្នាំ ដែលក្ដៅរោលរាលពេញខ្លួន ជំនួសការអាំងភ្លើងនឹងខំទ្រាំលេបផឹកថ្នាំដទៃៗ ទៀត តាមសម័យនិយម ដើម្បីសម្រួលសុខភាពមាតាឱ្យបានស្រួលឡើងវិញ ។

មាតាបិតាខំថ្នាក់ថ្នមថែរក្សាកូនគ្មានធ្វេសប្រហែសទេ ចិត្តវិញ្ញាណនៅជាប់នឹងកូនគ្រប់ពេលវេលា ពេលដេកទោះងុយងោកយ៉ាងណា ក៏ស៊ូនៅទ្រាំដរាបដល់កូនលក់ស៊ុបស្ងួន ទើបហ៊ានដេក កំពុងដេកលក់គ្រាន់តែឮមាត់កូនយំ ឬកូនរើបំរាស់មាតាបិតាភ្ញាក់ភ្លាម ស្ទុះក្រោកស្ទាបអង្អែល រកមើលនាយអាយសព្វគ្រប់ក្រែងមានសត្វអ្វីខាំទិចកូន ថ្នាក់ថ្នមលើកកូន ដោយដៃទាំងពីរផ្ទាប់នឹងឱរ៉ា បបោសអង្អែលបំពេលួងលោម ឱ្យកូនបានក្សាន្តចិត្តដេកលក់ទៅវិញ ទើបដាក់កូនទៅក្នុងអង្រឹង ឬលើដំណេក ។ ពេលកូនជុះនោម មាតាបិតាគ្មានខ្ពើមរអើមទេជូតជុសលាងដោយផ្ទាល់ដៃយ៉ាងស្និទ្ធអស់ពីចិត្តថ្លើម វេលាថ្ងៃនេត្រាទាំងគូ ខំពិនិត្យ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

រំពៃគយគន់ មើលស្រមោច ស្រមើល មូស រុយជាដើម ឬមួយមក ទិចខាំ គ្រាន់តែសត្វទាំងនោះមកជិតកូន ខំប្រវេប្រវាំបោសបក់ ហាក់ដូចជាភ័យខ្លាចខ្លាដំរីប្រហារជីវិតកូន ។

មាតាចាប់ផ្ដើមចិញ្ចឹមកូនដោយទឹកដោះ ដោយអំណាច ព្រហ្មវិហារធម៌របស់មាតា ជាតិលោហិតក្នុងហឫទ័យ ហូរចេញមក ជាពណ៌ស កើតជាអាហារទិព្វសំរាប់កូន ។

ក្បួនពេទ្យប្រកាសថា មាតាដែលបានចិញ្ចឹមកូន ដោយ ទឹកដោះខ្លួន ប្រសើរពេកណាស់ វៀរតែពេលដែលមាតាឈឺ ទើបគួរឱ្យផឹកទឹកដោះគោ ឬម្សៅជំនួសទំរាំបានជាវិញ ។

មាតាបង្ហូរលោហិតពីហឫទ័យចិញ្ចឹមកូន មិនមែនតិចទេច្រើន ខែណាស់ ខ្លះដល់បីបួនឆ្នាំក៏មាន អស់ទឹកដោះរាល់ពាន់លីត្រ ទំរាំ កូនចេះបរិភោគចំណីអាហារ ។

មាតាបិតាមិនមែនគ្រាន់តែចិញ្ចឹមរក្សាកូន ឱ្យធាត់ធំសាច់ ធ្ងន់ប៉ុណ្ណោះទេ ខំបង្ហាត់បង្រៀនកូន ឱ្យចេះសើច ឱ្យចេះនិយាយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ឆ្លើយបាទ! ចាស៎! ចេះក្រាបសំពះ គោរពសាសនា មហាក្សត្រ ចេះហៅមាតាបិតាក្រុមញាតិ នឹងឱ្យស្គាល់ថ្ងៃ ខែ ព្រះអាទិត្យ ព្រះចន្ទជាដើមទៀត គឺបង្ហាត់កូនឱ្យចេះដឹងសុជីវធម៌ វប្បធម៌ អារ្យធម៌ និងវឌ្ឍនធម៌គ្រប់ផ្នែក មុនគ្រូអាចារ្យទាំងអស់ ដែលមានក្នុងលោក ។ ដូច្នេះទើបមាតាបិតាមានឋានៈជា បុព្វាចារ្យ គឺអាចារ្យដើម ឬគ្រូដើម របស់កូនប្រុសស្រីថែមទៀត ។

មាតាបិតាចិញ្ចឹមបីបាច់រក្សាអប់រំកូន នឿយលំបាកពិតមែន តែមិនថ្ងូរ មិនធុញទ្រាន់បោះបង់ចោលកូនទេ, មួយថ្ងៃៗ នៅតែមានឱកាសប្រឡែងនឹងកូន ហៅកូនឱ្យសើច ឱ្យនិយាយ ឱ្យឆ្លើយ បើកូនគ្រាន់តែញញឹមរក ឬលាន់ឮសំឡេង កែ! ក! ដែលជាសញ្ញាឱ្យដឹងថា កូននិយាយរកខ្លួនតែបន្តិចប៉ុណ្ណោះ ក៏ធូរទ្រូងខ្សាក សប្បាយក្រៃណាសប្បាយ មានកម្លាំងព្រឹសភ្លេចអស់រលីងនូវការព្រួយលំបាកទាំងប៉ុន្មាន មានភក្ត្រាប្រកបដោយទឹកដមព្រហ្មវិហារស្រស់ប៉ប្រៃ ហត្ថាទាំងគូទ្រស្ទួយកូនថើបជប់ បញ្ចើច

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ហើយអួតសរសើរប្រាប់ក្រុមគ្រួសារ នឹងមិត្រថែមទៀតថា កូនខ្លួនចេះដឹងឆ្លាតវៃណាស់ ។

បើបែរជាកូនឈឺវិញ គ្រាន់តែក្តៅខ្លួន ឬ យំច្រើន មិនដេក មិនបៅដូចធម្មតានោះ មាតាបិតាទុក្ខព្រួយស្ទើរលត់ស្មារតីអស់ទៅហើយ ភ្លេចបាយភ្លេចទឹក តឹងទ្រូងស្ទើរប្រេះ លុះតែកូនបានជាធូរស្រាកស្រាន្តវិញ ទើបស្រស់មុខ នឹកឃើញបាយទឹក ។

តាំងពីកូនប្រសូតិមក មាតាបិតាថែរក្សាដោយការលើកដាក់បីព បំបៅដោះ បញ្ចុកបបរបាយ ផ្ចុតទឹក បោកគក់ជុសលាងមូត្រលាមកផ្ទាល់ដៃ, ទីដំណេកគ្រែពូក កន្ទេលខ្នើយ ដ៏ល្អស្អាត នឹងរូបកាយមាតាបិតា ក្លាយទៅជាបង្អន់សំរាប់កូន តែមាតាបិតាមិនធុញទ្រាន់អាក់អន់ចិត្តនឹងកូនទេ ព្រោះជាដួងជីវិតបណ្តូលចិត្តទៅហើយ នៅតែរីករាយទ្រាំទ្រភារៈធ្ងន់ធ្ងរយ៉ាងនេះរាប់ឆ្នាំ, ដល់កូនអាយុបានពីរបីឆ្នាំ ចេះដើរ ចេះរត់ ទើបបានធូរថយ ខាងការបីពរលើកដាក់ខ្លះ តែមានការរក្សាប្រុងប្រយ័ត្នរឹតតែលំបាក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ថែមទៀត សតិស្មារតីមាតាបិតានៅជិតជាប់នឹងរូបកូន ប្រុង ប្រយ័ត្នរក្សាការពារជាងដុំពេជ្រទាំងគ្រាប់ទៅទៀត ខ្លាចក្រែងកូន រអិលដួល ធ្លាក់ ឬចាប់ទាញអ្វីៗ រលំសង្កត់លើ ធ្លាក់បែកបាក់ មុតដៃជើង ឬខ្លាចកូនចាប់រើសអ្វីៗ ដែលមិនមែនចំណីមកស៊ី ឬ ក៏ខ្លាចកូនចេញទៅក្រៅរបងផ្ទះ ឆ្លងកាត់ផ្លូវថ្នល់ ក្រែងឡាន ម៉ូតូ កង់ សត្វមានពិស ទោចក្រយាន ឆ្កែឆ្មា រត់ប៉ះខាំ បុកកិនជាដើម ។

ការថែរក្សាប្រុងប្រយ័ត្នដូច្នេះ មិនមែនតិចឆ្នាំទេ ដរាបដល់ កូនអាយុប្រាំឬប្រាំមួយឆ្នាំ មានស្មារតីរឹងប៉ឹង ល្មមទៅរៀនវិជ្ជា កើត មាតាបិតារៀបចំគ្រឿងសិក្ខូបករណ៍ មានក្តារខៀន ដីស ជាដើម នាំកូនទៅចូលសាលារៀន មុននឹងឱ្យទៅរៀននោះ ខំផ្សាំចិត្តគំនិតកូន ក្នុងការសិក្សាជាច្រើនខែ មានបង្ហាត់ឱ្យចេះ សរសេរ ចេះរាប់ខ្លះ និងនិយាយសម្រួលចិត្តកូនឱ្យមានចំណង់ក្នុង ការសិក្សា ដោយពន្យល់ហេតុផលនៃចំណេះវិជ្ជា កាត់សំលៀក បំពាក់ឱ្យ នឹងឱ្យរបស់អ្វីៗ ជាគ្រឿងលើកទឹកចិត្តកូនថែមទៀត ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ថ្ងៃចូលរៀន មាតាបិតាជូនកូនទៅប្រគល់ជូនលោកគ្រូ ឬ ព្រះសង្ឃ ដែលជាគ្រូអាចារ្យ, បើកូនមានចិត្តក្លាហានក្នុងការរៀនសូត្រ មិនយំតាមមកផ្ទះវិញ មាតាបិតាសប្បាយចិត្តណាស់ ហាក់ដូចជាកូនចេះវិជ្ជាស្រេចទៅហើយ, បើកូនមិនចង់រៀន យំតាមមកផ្ទះ ឬគេចវេះខ្លាចសាលានោះ មាតាបិតាតឹងទ្រូងស្ទើរប្រេះ ហាក់ដូចជាអស់សង្ឃឹម ថាកូននឹងបានទៅជាអ្នកចេះដឹងនឹងគេ ។

តាំងពីកូនចូលរៀនមក មាតាបិតាក៏ហាក់ដូចជាចូលរៀនជាមួយកូនដែរ ពេលម៉ោងចូលរៀន ជូនទៅ, ពេលចេញ ទៅទទួល មួយថ្ងៃៗ បីបួនដង ជាច្រើនឆ្នាំទំរាំកូនធំ ទៅរៀនខ្លួនឯងបាន ព្រោះខ្លាចទៅតាមផ្លូវមានសត្វសាហាវខាំ ឬ ឡានប៉ះ បុកទង្គិច ជាន់ជាដើម ។

អាស្រ័យហេតុដែលចង់ឱ្យកូន គឺមនុស្សលោកចេះដឹងវិជ្ជាដូច្នេះហើយ ទើបព្រះរស់គឺមាតាបិតា នាំគ្នាបង្កើតអង្គការសិក្សាឡើងក្នុងលោក ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ប្រទេសមួយៗ មានក្រសួងសិក្សាធិការជាចាំបាច់ ក្រសួងនេះមានចែកជាច្រើនផ្នែក តាំងពីផ្នែកបង្ហាត់វិជ្ជាទាប ដរាបដល់វិជ្ជាខ្ពង់ខ្ពស់ មានវិជ្ជាបច្ចេកទេស វិទ្យាសាស្ត្រជាដើម ទាំងផ្លូវលោកធម៌ ព្រមទាំងវិជ្ជាកាយសិក្សា មានកីឡាអត្តពលកម្មជាដើមទៀត ។

ដូច្នេះ ក្រសួងសិក្សាធិការនេះ ពិតជាស្នាដៃរបស់ព្រះរស់បានបង្កើតឡើង ដើម្បីអប់រំសាងមនុស្សលោក ។

ករណីយកិច្ចមាតាបិតាចំពោះកូនក្នុងការសិក្សា មិនមែនចប់ត្រឹមជូនកូនទៅសាលារៀនប៉ុណ្ណោះទេ ពេលកូនត្រឡប់មកផ្ទះវិញ ខំពិនិត្យសាកសួរ តើគ្រូឱ្យរៀនពីអ្វីខ្លះ, បើកូនមិនទាន់យល់ ជួយបង្ហាត់ពន្យល់ថែមទៀត ដាស់តឿនឱ្យខំរៀន ខំទន្ទេញ ឱ្យបានយល់ចេះចាំ កុំឱ្យគ្រូស្តីបន្ទោស ។ ពេលយប់ដេកមិនលក់ទេ ចាំដល់កូនឈប់រៀនដេកលក់ ទៅមើលកូនក្រែងដេកមិនបានដណ្តប់ៗ ដេកច្រងេងច្រងាង រៀបចំដណ្តប់ឱ្យ ទើប

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

មាតាបិតាធ្មេចដេកលក់ ។

រយៈវេលាដែលមាតាបិតាឱ្យកូនរៀនវិជ្ជានេះ មិនមែន,ទេ ចំនួនដល់ម្ភៃឆ្នាំ តាំងពីកូននៅកុមារកុមារីដល់ពេញកំឡោះក្រមុំ, បើកូនរៀនពូកែ ចេះឱ្យរៀនទៅទៀត ហើយរ៉ាប់រង ទំនុកបំរុងគ្រប់យ៉ាងទាំងអស់ តាំងពីសំលៀកបំពាក់ប្រដាប់រៀន ចំណីអាហារ លុយកាក់ចាយជាដើម ។

ពេលកូនប្រឡងម្តងៗ មាតាបិតាបន់ព្រះសំពះទេវតាបួងសួងសុំឱ្យកូនជាប់ បើបានជាប់មែនសប្បាយចិត្តណាស់ អួតសរសើរឱ្យរង្វាន់លើកទឹកចិត្តឱ្យកូនខំរៀនថែមទៀត, តែបើធ្លាក់វិញ មាតាបិតាព្រួយចិត្តក្រៃលែង ក្រែងកូនខូចចិត្តទញ់តុះគំនិត ទំនិយាយលួងលោម ឱ្យកូនបានក្សាន្តចិត្ត ប្រឹងរៀនតទៅទៀត ។

ដល់ពេញកំឡោះក្រមុំ ត្រូវទៅបំពេញវិជ្ជាជាន់ខ្ពស់នៅទីឆ្ងាយពីខ្លួន មាននៅទីក្រុង ឬ នៅបរទេសជាដើម មាតាបិតាគិតគូរចំរើនណាស់ និយាយទូន្មានផ្តែផ្តាំកូនសព្វយ៉ាង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ឱ្យកូនបានស្ថិតនៅក្នុងសេចក្តីថ្លៃថ្នូរ តាមគតិបណ្ឌិត នឹងរៀបចំប្រដាប់ប្រដាសំលៀកបំពាក់ អាហាររូបករណ៍ជាដើម ជូនដំណើរកូនទៅផ្ញើទុកដាក់ឱ្យអ្នកដែលកូនត្រូវស្នាក់អាស្រ័យ ។

ពេលត្រឡប់ពីជូនកូនមកផ្ទះវិញ មាតាបិតាអាឡោះអាល័យណាស់ មិនចង់ឱ្យកូនឃ្លាតជុតពីរង្វង់ចក្ខុទេ ទោះពេញកំឡោះក្រមុំហើយក៏ដោយ ក្រែងមិនបានសុខស្រួល ដូចជានៅក្នុងការគ្រប់គ្រងរក្សារបស់ខ្លួនៗ មានមាតាបិតាខ្លះ អាឡោះអាល័យកូនខ្លាំងដល់ស្រក់ទឹកភ្នែកក៏មាន ។

ឱ! មាតាបិតាអើយ ពិតជាព្រះរស់របស់កូនមែន! តែមានកូនខ្លះ គ្មាននឹកឃើញដល់រឿងនេះទេ បានធំខ្លួនពេញកំឡោះក្រមុំស្គាល់ទិសទីហើយ ក៏គិតតែភ្លើតភ្លើនក្នុងអំពើពាលា, មាតាបិតាបញ្ជូនឱ្យទៅរៀនវិជ្ជា គិតតែស្នេហា ស៊ីផឹកដើរលេងសប្បាយ ហើយភូតភរកុហក បោកបញ្ឆោតម៉ែឪ ដែលជាព្រះបង្កើតក្បាលខ្លួន ដោយយកការរៀនសូត្រ ជាខែលបាំង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មុខ លំអុកសុំលុយកាក់ម៉ែឪថាយកទៅរៀន, ឯម៉ែឪមិនឱ្យកូនសុំធូនមាត់ទេ ខំខ្វះកកាយពីទូហិបឱ្យ បើមិនគ្រប់គ្រាន់តាមចំនួនដែលសុំ ស៊ូប្តូរលក់បញ្ចាំកើ្តកោះស្រែចំការ យកប្រាក់ឱ្យកូនទៀត ។ ឯកូនចង្រៃ កូនអកតញ្ញូ កូនបកស្បែកម៉ែឪលក់ ដល់បានប្រាក់ហើយ យកទៅហ៊ុហាទិញខោអាវស្បែកជើងទឹកអប់ស្អិតស្អាងដើរចង់ស្រី យកប្រាក់ដែលកើតពីញើសឈាមម៉ែឪ ទៅចិញ្ចឹមស្រីឯណោះវិញព្រងើយ ។

ចំណែកមាតាបិតានឹកសង្ឃឹមថាកូនបានប្រាក់ទៅ មុខជាខំរៀនសូត្រហើយ ដល់កូនទៅផុត ខំអុចធូបបន់ព្រះសំពះទេវតាទៀត បើកូនអកតញ្ញូបោកបញ្ឆោតព្រះរស់ ដែលបង្កើតក្បាលខ្លួនទៅហើយ ។

មាតាបិតា កាលបើបានដឹងថាកូនប្រព្រឹត្តដូច្នោះ ព្រួយចិត្ត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ណាស់ សេចក្ដីសង្ឃឹមទាំងប៉ុន្មានរលត់អស់ អាម៉ាស់មុខខ្មាស់ញាតិជិតខាង, តែមាតាបិតាមិនចោលកូនទេ មិនទាន់អស់ចិត្តទេ ខំរិះរកមធ្យោបាយអប់រំកូនទៀត ក្រែងបានល្អឡើងវិញ ។

នេះហើយជាភ័ស្ដុតាងទឹកហឫទ័យ ប្រកបដោយព្រហ្មវិហារធម៌ដ៏បរិសុទ្ធស្អាតរបស់ព្រះរស់ ដែលប្រោះព្រំទៅលើកូនគ្មានរើសមុខ ទោះកូនល្អក្ដី អាក្រក់ក្ដី ខ្ជិនខ្ជាក់គថ្លង់ឆ្កួតលីលាដូចម្ដេចក្ដី សុទ្ធតែជាកូនសំឡាញ់បណ្ដូលចិត្តម៉ែឪទាំងអស់ ដូចទឹកភ្លៀង ដែលធ្លាក់ចុះពីអាកាសមកផែនដី មិនរើសថាទីល្អអាក្រក់ ទាបខ្ពស់ទេ តែងតែធ្លាក់ស្រោចប្រោះព្រំស្មើគ្នាទាំងអស់គ្រប់ស្ថាន ។

## ការសាងមនុស្សលោកគ្រាទី ៣

( ពីពេញកំឡោះក្រមុំ ដល់អវសានជីវិត )

ព្រះរស់គឺមាតាបិតា ខំចិញ្ចឹមរក្សាអប់រំកូនអស់រយៈវេលា ១៨ ឬ ១៩ ឆ្នាំ ទើបកូនបានធំពេញកំឡោះក្រមុំ ដែលហៅថា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុង ចន្នី

មនុស្សគ្រប់ការ កើតជាពលរដ្ឋ ពលលោកពេញលក្ខណៈបាន។

កាលកូនធំពេញកំឡោះក្រមុំដូច្នេះហើយ, មាតាបិតាប្រុងប្រយ័ត្នណាស់ មិនបណ្តែតបណ្តោយឱ្យច្រេះស្នឹម គឺអមនុស្សធម៌ស៊ី ឬ ដុះចាប់នូវគំនិត ចរិយាមារយាទកូនទេ រឹតតែមានភារៈធ្ងន់ៗ ក្នុងការគ្រប់គ្រងរក្សា អប់រំ ដុសខាត់ចិត្តគំនិតមារយាទច្រើនប្រការទៀត ព្រោះកូនធំហើយ ចិត្តគំនិតក៏ធំដែរ ផ្លែកពីកុមារកុមារី មានសរសៃវិញ្ញាណក្លាហាន អាចទាញគំនិតចរិយាមារយាទឱ្យលង់លុះទៅក្នុងអបាយមុខ ស្រី ស្រា ល្បែងភ្នាល់ ដែលជាប្រភពឱ្យកើតអមនុស្សធម៌គ្រប់យ៉ាង មានលួច ប្លន់ កាប់ចាក់ កុហក ឆបោកជាដើម ។

កាលនៅពីតូច មាតាបិតានឿយព្រួយលំបាករញ៉ីករញ៉ុកទាំងយប់ទាំងថ្ងៃមែន តែទុកដូចជាការយល់សប្តិទេ គ្រាន់តែកូនញញឹមរកបន្តិចបន្តួច ក៏ភ្លេចទុក្ខព្រួយនោះអស់ទៅហើយ, ឯកូនធំពេញកំឡោះក្រមុំ ដែលមិនស្តាប់តាមឱវាទម៉ែឪនោះ ទើប

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រឹន ចន្នី

កើតទុក្ខធំ ធំជាប់មិនរសាយ ស៊ីមិនបាន ដេកមិនលក់ បក់មិនល្ហើយ អាម៉ាស់មុខដូចគេទទូរស្បែកខ្លែ ។

ពេលថ្ងៃ ឬ យប់ បើកូនចេញដើរទៅណា ម៉ែឪនៅមិនសុខ ដេកមិនលក់ទេ ស៊ូទ្រាំចាំទ្វារ បើយូរហួសពេលធម្មតា ខំបើកទ្វារ បង្អួចអើតមើលផ្លូវកូន សំឡឹងមើលស្ទើរជ្រុះគ្រាប់ភ្នែក ត្រចៀកទាំងគូប្រឹងស្តាប់ ឮអស់ហើយសំឡេងសូរស័ព្ទ អ្វីៗចំណែកខាងអារម្មណ៍ ខំប្រឹងជ្រើសរើសរាវរកសំឡេងកូន បើជួនជាឮថាមានគេឈ្លោះទាស់ទែងគ្នា ឬ មានហេតុអន្តរាយផ្សេងៗនោះ ម៉ែឪតក់ស្លុតស្មារតីអស់ ទុក្ខព្រួយអន្ទះសាដូចមាន់រកពងភ័យក្រែងកូនទៅជួបនឹងហេតុអន្តរាយនោះៗ, បើទុកជាចាស់ជរាភ្នែកងងឹតហើយ ក៏ខំស្ទុះទៅរកកូន ឬក៏ពឹងពាក់គេឯងឱ្យទៅរកជំនួស, លុះតែបានកូនមកដល់ផ្ទះទើបធ្មេចភ្នែកជិត ។

ឯកូនប្រុស និងកូនស្រីទាំងពីរពួកនេះ ដែលពេញកំឡោះក្រមុំហើយ មាតាបិតាព្រួយថែរក្សាដូចគ្នាគ្មានលើសខ្វះទេ, ព្រោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ភេទស្រីធម្មតាគាត់តែងមកប្រកបដោយភាពទន់ខ្សោយ ហើយច្រើនសុភាព ទាំងចិត្តគំនិត និងកាយវិការ មិនរឡេមរឡាម ដើរលេងមានមិត្តភ័ក្តជ្រួលជ្រើមក្នុងអបាយមុខ ស៊ីផឹក កាប់ចាក់ ថែរក្សាព្រហ្មចារី[១] ដែលជាហេតុឱ្យខូចអនាគតខ្លួន នឹងថោកទាបដល់វង្សត្រកូល ។

ប៉ុន្តែមាតាបិតា មិនហាមឃាត់បិទសិទ្ធិកូន មិនឱ្យទាក់ទងនឹងបុរសកំឡោះនោះទេ គឺបើកឱ្យមានវិស្សាលភាពចំពោះមនុស្សលោកទូទៅគ្រប់ប្រភេទ ដូចជាឱ្យទៅរៀនវិជ្ជា ឱ្យធ្វើទាហាន ឱ្យធ្វើកីឡា និងឱ្យធ្វើការក្នុងក្រសួងនានាជាដើមដោយសេរី ទាំងមិនហាមឃាត់សេចក្តីស្នេហារបស់កូនទៀត, ព្រោះការទាក់ទង

១-តាមបែបត្រឹមត្រូវ ព្រហ្មចារី សំរាប់ហៅបុរសកំឡោះ ព្រហ្មចារិនី សំរាប់ហៅស្ត្រីក្រមុំ, ប៉ុន្តែអ្នកស្រុកធ្លាប់ហៅ ព្រហ្មចារីនេះចំពោះតែស្ត្រីក្រមុំ បាក់មាត់យូរយារណាស់មកហើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

រាប់អាន នឹងសេចក្តីស្នេហា ជាការចាំបាច់របស់មនុស្សលោក កុំឱ្យតែប្រព្រឹត្តកន្លងប្រពៃណីខូចព្រហ្មចារី ដែលពិភពលោកតែងត្មះតិះដៀលប៉ុណ្ណោះ ។ ឯវិជ្ជានឹងការងារទាំងឡាយ មិនមែននាំឱ្យខូចព្រហ្មចារីស្ត្រីទេ គឺជាជំនួយយ៉ាងសំខាន់ អាចឱ្យស្ត្រីស្គាល់តម្លៃខ្លួន ចេះរក្សាព្រហ្មចារីបានបរិសុទ្ធ មិនឆោតល្ងង់ចាញ់បោកប្រុសៗ ឯគំនិតមារយាទគ្មានសិល្បៈ ឆោតល្ងង់ខ្លៅនោះទេតើ ដែលនាំឱ្យខូចព្រហ្មចារី របស់ស្ត្រីទាំងឡាយ ។ ដូចស្រីក្រមុំជំនាន់មុន ដែលគ្មានការសិក្សា មាតាបិតាមិនហ៊ានបណ្តោយឱ្យទៅណាទេ ឃុំទុកតែក្នុងផ្ទះ បើទៅទីណាម្តងម្កាលមានមនុស្សបណ្តើរម្នាក់ ឬ ពីរនាក់ទៅទើបបាន ខ្លាចក្រែងឆោតល្ងង់ឱ្យប្រុសឈ្នាលបោកបញ្ឆោតមើលងាយ ។ ឯសព្វថ្ងៃនេះក៏ដូច្នោះដែរ បើស្រីក្រមុំណាគ្មានការសិក្សា ឬសិក្សាហើយតែមិនបានចេះដឹងនៅល្ងង់ខ្លៅ ក៏មាតាបិតាមិនហ៊ានបើកសិទ្ធ ឱ្យរួចពីការឃុំឃាំងនិងការបណ្តើរនោះដែរ បើទុកជាហួសសម័យបរមាណូនេះទៅ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មុខទៀត ក៏ត្រូវតែធ្វើដូច្នេះ ព្រោះស្រីក្រមុំដែលខ្វះការសិក្សា គ្មានសិល្បៈក្នុងគំនិត ប្រៀបដូចជាមាសពេជ្រដែលនៅកណ្ដាល វាលក្រៅផ្ទះ ចោរអាចលួចប្លន់បានដោយងាយ អនាគត និង វង្សត្រកូលរបស់ស្រីនោះ ក៏វិនាសអាប់ឱនទៅដោយងាយដែរ ។

អាស្រ័យហេតុនេះ ទើបមាតាបិតាខំប្រៀនប្រដៅ ពន្យល់ អប់រំកូនស្រី ឱ្យចេះថែរក្សាខ្លួន ឱ្យដឹងថា ស្រីក្រមុំទាំងឡាយ បើចេះរក្សាព្រហ្មចារីខ្លួនបានបរិសុទ្ធ ទើបមានតម្លៃ ដូចពេជ្រ ទាំងគ្រាប់ ឬដូចជាមាសទឹកដប់ មានសេរីសួស្ដី មានឫទ្ធានុភាព អាចផ្ចាញ់សត្រូវ គឺបុរសឡេះឡោះបានគ្រប់ទិសទី ឱ្យបាក់បបខ្លបខ្លាច សូម្បីតែពួកទេវតាក៏សរសើរឱ្យពរជ័យដែរ ។ ព្រហ្មចារីនេះហើយ ជាដួងជីវិតរបស់ស្រីក្រមុំ ជាកំណប់ទ្រព្យ នឹងជាឃីហោរបស់ស្រីក្នុងលោក, បើព្រហ្មចារីវិនាសទៅ ដោយខុសគន្លងប្រពៃណីហើយ ជីវិតរបស់ស្រីនោះ ក៏ឈ្មោះថាបាត់បង់ទៅដែរ សិរីសួស្ដីគ្រប់ជំពូកក៏រលត់រលាយទៅ ទេវតាស្អប់ខ្ពើមតែង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ផ្គន្ធាទោសគ្រប់ពេល សត្រូវហ៊ានមើលងាយគ្រប់ទិសទី ។

ស្ត្រីក្រមុំដែលគ្មានការតស៊ូរក្សាព្រហ្មចារីរបស់ខ្លួន ឱ្យបានគង់វង្ស ឈ្មោះថាស្លាប់ទាំងរស់ស្អុយទាំងស្រស់ ទៅទីណាមានរុយក្បាលខៀវ គឺប្រុសពាលាតាមញាំញីគ្រប់ទិសទី, ស្ត្រីនោះ បើទុកជាស្លៀកសំពត់ហូលព្រៃ រចនាដោយមាសពេជ្រយ៉ាងណា ក៏ទុកដូចជាស្រាតខ្លួនទទេ នៅចំពោះមុខមហាជន ។ ពិភពលោកសន្មតស្រីនោះ ជាញីថោកទាបដូចសត្វតិរច្ឆាន ។

ស្ត្រីក្រមុំទាំងឡាយ គួរតែស្គាល់សិទ្ធមហាអំណាចរបស់ខ្លួនដែលជាម្ចាស់ជីវិត នៃសេចក្តីស្នេហារបស់បុរសក្នុងលោក, ធម្មតាសេចក្តីស្នេហារបស់បុរស លុះតែស្ត្រីដាក់ទានឱ្យ ទើបមានជីវិតមានសកម្មភាពឡើងបាន ។

ស្ត្រីក្រមុំនេះហើយ ជារាជិនីនៃសេចក្តីស្នេហារបស់មនុស្សលោក សោយរាជ្យក្នុងនគរកាមទេព មានឫទ្ធានុភាពធំអស្ចារ្យ ជាស្តេចចក្រពត្រាធិរាជ កាន់អំណាចផ្តាច់ការ ខាងស្នេហាគ្រប់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

យ៉ាងទាំងអស់ គ្មានបុរសណាអាចច្បាំងយកជ័យជំនះបានទេ ។

ម្យ៉ាងទៀត ស្ត្រីជាកូនសោនៃសេចក្តីស្នេហារបស់បុរស បើស្ត្រីចាក់សោជិត កាន់កូនសោជាប់នៅដៃហើយ សូម្បីបុរសក្នុងពិភពលោកទាំងមូល ដែលប្រដាប់ដោយអាវុធបរមាណូ នាំគ្នាមកច្បាំងដណ្តើមយកស្នេហានោះ ក៏មិនបានដែរ, លុះតែស្ត្រីឱ្យដៃទើបប្រុសហ៊ានចូលក្នុងព្រំដែនស្នេហាបាន ដូចភាសិតមួយបទក្នុងគម្ពីរបញ្ចតន្ត្រថា:

"ល័ក្តក្រហម ទាល់តែគេឈ្លីច្របាច់
ទើបចេញក្រហមយ៉ាងណា ប្រុសទាល់តែស្រីឱ្យដៃ
ទើបស្នេហាយ៉ាងនោះដែរ" ។

ភាសិតបុរាណថា:

"ទាល់តែទំពក់វាទៅ ទើបញ្ចៅវាមក"

មួយទៀតថា:

"ទឹកហូរតាមប្រឡាយ ទន្សាយបោលតាមប្រឡោះ"

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

មួយទៀតថាៈ

"ភ្លើងឆេះពីសម្រាម អង្កាមកើតពីស្រូវ" ។

មួយទៀតថាៈ

"ត្រឡាចវារទៅ ល្ពៅវារមក" ។

មួយទៀតថាៈ

"មានដំបៅទើបរុយវារោម មានសម្រាមទើបឆ្កែវាផុះ" ។

មួយទៀតថាៈ

"ចោរក្នុងឱ្យដៃ ទើបចោរក្រៅហ៊ានចូលលុក" ។

ពុទ្ធភាសិតថាៈ

"មានហេតុ ទើបមានផល" ។

ព្រោះហេតុនោះ ស្ត្រីក្រមុំ ពិតជាមានសិទ្ធិដាច់មុខ ក្នុងការរក្សាព្រហ្មចារីរបស់ខ្លួន, គ្មាននរណា អាចចូលជ្រៀតជ្រែករារាំងបានទេ បើព្រហ្មចារីបរិសុទ្ធ គឺខ្លួនបរិសុទ្ធ បើមិនបរិសុទ្ធទេ ក៏ជាស្នាដៃរបស់ខ្លួននោះឯង, ព្រោះធម្មជាតិបានប្រគល់សិទ្ធិ

WAT KHEMARARATANARAM

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

អំណាចស្នេហាគ្រប់ទាំងអស់ ក្នុងកណ្ដាប់ដៃខ្លួនហើយ ។

គួរកញ្ញាទាំងឡាយ កុំគ្រាប់តាមស្ត្រីក្រមុំខ្លះ ថោកទាបមិនស្គាល់តម្លៃខ្លួន ដែលធម្មជាតិបង្កើតមក ជារាជិនីនៃសេចក្ដីស្នេហាហើយ គ្រាន់តែបុរសគម្រក់ក្ដក់ប៉ក់ ក៏ដោយតាមរ៉ុយ ដូចសត្តិរច្ឆានញី ដោយឈ្មោលនោះឡើយ នាំឱ្យថោកទាបវង្សត្រកូល និងប្រទេសជាតិ ។ ពួកស្រីធុនហ្នឹងហើយ ដែលបង្កើតពូជស្រីផ្កាមាសពាសពេញលោក ។

ព្រះរស់គឺមាតាបិតា មិនធ្វេសប្រហែសទេក្នុងរឿងនេះ, កាលបើកូនគ្រប់ការហើយ លោកប្រាប់ពន្យល់ភ្លាម អំពីការណ៍អាថ៌កំបាំងការពារទុកជាមុនតាមដំណើរជីវិតមនុស្ស ដែលលោកបានឆ្លងកាត់ បានពិសោធន៍រួចមកហើយ ក្រែងកូនទៅធោតល្ងង់នាំឱ្យខូចអនាគត និងវង្សត្រកោល ។

មាតា បានតាំងខ្លួនលោកជាមិត្រយ៉ាងជិតស្និទ របស់កូនស្រីនិយាយប្រាប់អាថ៌កំបាំងរបស់ស្ត្រីភេទគ្រប់យ៉ាងដល់កូន ធ្វើឱ្យ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

កូនទុកចិត្តដូចជីវិតតែមួយ អាចហ៊ានប្រាប់អាថិកំបាំងដល់លោក បាន ដូចជាប្រាប់អំពីមានផ្ការដូវជាដើម ។ មាតាបានចងចាំយ៉ាង ច្បាស់ អំពីពេលវេលានៃផ្ការដូវរបស់កូន, លុះដល់ពេលហើយ តែងសាកសួរពិនិត្យហេតុផល បើកូនរាំងរដូវដោយមានរោគអ្វីៗ បៀតបៀន មាតាភ័យណាស់ ខំរកពេទ្យធ្មបឱ្យពិនិត្យមើល រកថ្នាំ មកព្យាបាល ឱ្យបានស្រួលមានប្រក្រតីទៀងទាត់ឡើងវិញ ។

ការណ៍ដែលមាតាត្រួតពិនិត្យកាលបរិច្ឆេទ នៃផ្ការដូវកូន យ៉ាងនេះ ដើម្បីការពារហេតុ ២ យ៉ាងគឺៈ ១.ការពារសុខភាព, ២.ការពារអនាគត ក្រែងកូនភ្លាំងភ្លាត់ក្នុងសេចក្តីស្នេហាដល់មាន គភ៌ មាតាបានដឹងភ្លាម មិនហួសពេលវេលា អាចជួយសម្រួល អនាគតកូនបាន មិនអាម៉ាស់មុខ ។

ឱ! កញ្ញាទាំងឡាយ នាងចំជាមានសំណាងមែន បានមក កើតក្នុងគ្រួសារមាតាបិតា, គ្មានមិត្រឯណាប្រសើរឯក អាចជួយ នាងបានស័ក្តសិទ្ធ ក្នុងពេលដែលនាងភ្លាំងភ្លាត់ធ្លាក់ទៅក្នុងអន្លង់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ស្នេហាទេ មានតែមាតាបិតានេះហើយជាមហាឥសី អាចជប់អនាគតដ៏រុងរឿងឱ្យនាងបាន, ដូច្នេះចូរនាងស្មោះត្រង់ កុំខ្មាស់អៀន កុំលាក់បិទអាថ៌កំបាំងរបស់នាង ចំពោះមាតាបិតាឱ្យយូរហួសពេលវេលាឡើយ ត្រូវជំរាបប្រាប់លោកភ្លាមៗ ព្រោះក្នុងលោកនេះ មានតែមាតាបិតាទេ ជាព្រះដ៏ស័ក្តសិទ្ធរបស់នាង ។

ឯកូនកំឡោះវិញ ពិតមែនតែគ្មានព្រួយក្នុងការរក្សាព្រហ្មចារី, ក៏មាតាបិតាមិនមែនហួតកន្ទុះលែងចោល ដូចគោក្របីនោះទេ ខំរំលឹកទូន្មានស្តីប្រៀនប្រដៅរាល់ពេលវេលា ដោយផ្ទាល់ខ្លួនផង យកទៅផ្ញើនឹងគ្រូអាចារ្យ ឬ អ្នកដែលមានការពិសោធន៍ច្រើនជួយប្រៀនប្រដៅ ឱ្យកូនមានបែបបទល្អ ដរាបដល់ឱ្យបួសក្នុងពុទ្ធសាសនាថែមទៀត ដើម្បីការពារអនាគតកូនកុំឱ្យភាន់ច្រឡំទៅប្រព្រឹត្តអំពើពាលាអាវ៉ាសែ ដែលអាចឱ្យក្លាយខ្លួនទៅជាអ្នកប្រមឹក អ្នកលេង លួចប្លន់ឆបោក កាប់ចាក់ជាដើម នាំឱ្យថោកទាបដល់វង្សត្រកូល និងប្រទេសជាតិ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ដូច្នេះអ្នកកំឡោះទាំងឡាយ! គួរអាណិតអាសូរមាតាបិតាអ្នក កុំប្រព្រឹត្តអបាយមុខគ្រប់យ៉ាង មានលេងស្រី ដែលជាហេតុឱ្យខូចព្រហ្មចារីជាដើម ។ ឯព្រហ្មចារីរបស់បុរស ងាយថែរក្សាណាស់ គ្មាននរណារុកគួនតាមបៀតបៀន ដូចព្រហ្មចារីរបស់ស្ត្រីទេ គួរតែអ្នកថែរក្សាឱ្យបានបរិសុទ្ធគង់វង្ស នៅក្នុងភាពកំឡោះ បើមិនបានវិសេសលើសពួកកញ្ញាដែលមានភេទទន់ខ្សោយជាងនោះ ក៏ឱ្យបានស្មើគ្នាទៅចុះ កុំឱ្យចាញ់ប្រៀបពេក ។

តាមពិត មានកំឡោះភាគច្រើនណាស់ ដែលគ្មានការតស៊ូរក្សាព្រហ្មចារី បណ្ដោយឱ្យអន្តរាយ ក្លាយខ្លួនពោះម៉ាយទាំងក្មេង ព្រោះតែការភ្លើតភ្លើន ស្រើបស្រាល តាមមិត្រសំឡាញ់ខិលខូចដែលមានព្រហ្មចារីពុករលួយ វានាំយកវ័យកំឡោះត្រឡាំងរបស់ខ្លួនទៅប្រគល់ឱ្យស្រីតាក់ស៊ី ពេស្យា ផ្កាមាសជាដើម ជាន់ឈ្លួចឈ្លីចោល ហើយវាបំបួសចិត្តគំនិត ឱ្យស្រវឹងញៀនញ៉ាមញយខូចសតិបញ្ញា ការរៀនសូត្រ ខូចការងារគ្រប់យ៉ាង ខ្លះវាចម្លង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មេរោគទុកយកទៅបំផ្លាញអនាគតភរិយា នឹងកូនចៅទៀត ។ ដល់មានគ្រួសារទៅ នាំឱ្យខូចសេចក្ដីសន្ដោស ចំពោះភរិយា បណ្ដាលឱ្យមានស្រីញីផ្ដេសផ្ដាស ពាសវាលថែមទៀត ។ នេះជាទោស នៃការខូចព្រហ្មចារីរបស់បុរស ។ ពួកបុរសធុនហ្នឹងហើយ ដែលបង្កើតពូជប្រុសផ្កាប្រាក់ គឺសំដីងប្រុសពាសពេញលោក ហើយចូលចិត្តនាំបំបួសក្មេងកំឡោះៗ ទាំងឡាយ ឱ្យខូចព្រហ្មចារី និងបោកបញ្ឆោតស្រីក្រមុំដែលនៅឆោតល្ងង់ ឱ្យខូចព្រហ្មចារី កើតជាស្រីផ្កាមាសថែមទៀត ។

រឿងនេះមានកំឡោះភាគច្រើនយល់ថា ការលេងស្រីម្ដងម្កាល ជាការស្រស់ស្រូបកំសាន្ដចិត្ត ឬ ជាការពិសោធន៍ ទំរាំមានគូរស្រករ នេះពេញជាខុសធំ ប្រៀបថ្នាំពិសជាអាហារទិព្វ, ព្រោះមើលងាយស្រីហើយ ព្រហ្មចារីក៏វិនាសអន្ដរធានទៅភ្លាម ក្នុងពេលនោះដែរ ភេទកំឡោះបាត់បង់ទៅ កើតជាពោះម៉ាយអស់មួយជីវិត, ដល់ពេលមានគូរស្រករ ទោះបីទំរៀបអាពាហ៍ពិពាហ៍

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មង្គលធំដុំយ៉ាងណា ក៏ខ្លួននៅតែពោះម៉ាយៗ ដដែល ហើយចូលក្នុងការធរបោក បន្លំដោយទុកចិត្ត ចំពោះមាតាបិតាទាំងសងខាងដែលជាអ្នកមានគុណ ព្រមទាំងករិយាខ្លួនទៀតផង, ព្រោះលោកអ្នកទាំងនោះមិនដឹងអាថ៌កំបាំង ។ ដែលខ្លួនទំលាក់នោះទេ សំគាល់ថាជាមនុស្សកំឡោះ ។ បើខ្លួនមិនបរិសុទ្ធហើយ លទ្ធផលរបស់ខ្លួនក៏មិនបរិសុទ្ធដែរ, ដូចពុទ្ធភាសិតថាៈ

"ដើមដូងផ្លែដូង ដើមស្វាយផ្លែស្វាយ" ។

បើមិនបានទទួលផលផ្ទាល់ខ្លួនទេ មុខជាបានទទួលផលនោះ ពីកូនចៅខ្លួនមិនខាន ។

មួយទៀតថាៈ

"នាងរត់រកអ្នក មេខាតល័ក្ខណ៍រត់រកអាកំបាក់ទន្សា..."។

បើយើងមិនមែនជានាងក្រមុំ អ្នកកំឡោះ មុខជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ជួបនឹងមេខាតល័ក្ខណ៍ ឬ អាកំបាក់ទន្សាពុំខាន បើមិនផ្ទាល់ខ្លួនយើង ក៏ពីកូនចៅយើង ។

ឯខ្លួនយើងពិតជាអ្នកបំផ្លាញលោក ព្រោះបានសាបបណ្តុះពូជអាក្រក់ទុកក្នុងលោក ។

# អំពីតុល្យភាព

ការដែលបុរសស្ត្រី បានស្ថិតនៅក្នុងភាពក្រមុំកំលោះនេះ បើប្រៀបធៀបគ្នា រកតុល្យភាព ឃើញថាៈ ពួកស្រីក្រមុំមានប្រៀបជាង ប៉ុនរក្សាព្រហ្មចារីបរិសុទ្ធ បានស្ថិតនៅក្នុងភាពក្រមុំប្រហែលជា ៨០ ឬ ៩០ ភាគរយ (៨០% ឬ ៩០%) ទំរាំដល់ពេលមានស្វាមី ។ ឯពួកកំលោះវិញ កំសាកណាស់ ដើរមិនទាន់សម័យក្នុងរឿងនេះសោះ រក្សាព្រហ្មចារីបរិសុទ្ធ បានស្ថិតនៅក្នុងភាពកំលោះ ប្រហែលតែ ១០ ឬ ២០ ភាគរយទេ (១០% ឬ ២០%) ទំរាំដល់ពេលមានភរិយា ។ មកអំពីពួកបុរសមិនសូវមានសុជីវធម៌ក្នុងរឿងនេះ ចំពោះស្ត្រីទាំងឡាយ ។ មួយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ទៀតបុរសច្រើនប្រមាថ ដោយអាងថាការខូចព្រហ្មចារីរបស់ខ្លួន មិនឮសូរក្តុងក្តាំងដូចគ្រាប់បែកទេ អាចបន្លំពាក់មុខកំឡោះ បោកប្រាស់យកប្រពន្ធក្រមុំបានដោយងាយ ។ មានកំឡោះភាគច្រើនក្នុងលោក មិនទាំងដឹងថាប្រព្រឹត្តដូច្នោះ ខូចព្រហ្មចារីខ្លួនផង ។ ថែមទាំងមិនដែលគិតថា ខ្លួនមានព្រហ្មចារីបរិសុទ្ធ ទើបបានឈ្មោះថាកម្លោះនោះទេ ធ្លាប់ដឹងថា មានព្រហ្មចារីតែពួកស្ត្រីក្រមុំ ។ ឯខ្លួនចង់ប្រព្រឹត្តធ្វើដូចម្តេចក៏នៅតែកំឡោះដដែល ព្រោះភាពកំឡោះរបស់ខ្លួន ស្ថិតជាប់ជាប់ដែកថែបទៅទៀត ។ ការយល់ដូច្នេះ ។ ប្រកបដោយមោហៈធំណាស់ ទើបពួកកំឡោះក្នុងលោក មានព្រហ្មចារីពុករលួយ ពោះម៉ាយទាំងក្មេងអស់ ៨០ ឬ ៩០ ភាគរយ (៨០% ឬ ៩០%) ។

ដូច្នេះឃើញថាៈ ស្ត្រីក្រមុំទាំងឡាយ ច្រើនមានស្វាមីពោះម៉ាយ, ឯបុរសពោះម៉ាយទាំងឡាយ ច្រើនតែមានភរិយាក្រមុំ ។ នេះជារឿងចំឡែកមួយ ក្នុងកាមលោក ។

គួរអ្នកកំឡោះទាំងឡាយ មានសុជីវធម៌ក្នុងរឿងចំឡែកនេះ ចំពោះស្ត្រីក្រមុំទាំងឡាយផង! ព្រោះស្ត្រីនេះហើយជាមាតានៃពិភពលោកយើង មានតែអ្នកកំឡោះទាំងឡាយទេ ដែលជាថៅក្រមអាចរកយុត្តិធម៌ ជូនមាតានៃពិភពលោកយើងនេះបាន ហើយអាចបន្ថយចំនួនរឿងចំឡែកអកុសលនេះ ពីក្នុងពិភពលោកបានផង ។

# អំពីសិរិយាបថ

ព្រះរស់គឺមាតាបិតា មិនមែនអស់ការប្រៀនប្រដៅអប់រំបុត្រធីតា ត្រឹមប៉ុណ្ណោះទេ ទោះបីកូនបានរៀនចេះដឹងហើយក៏ដោយ លោកនៅតែខ្វល់ខ្វាយប្រៀនប្រដៅ អប់រំបន្ថែម ឱ្យបានវិសេសវិសាលគ្រប់វិស័យទាំងអស់ មានឱ្យចេះធ្វើការចិញ្ចឹមជីវិត ឱ្យចេះដឹងសុជីវធម៌គ្រប់យ៉ាង ដូចជាពេលដេក លោកទូន្មានឱ្យដេកប្រកបដោយសុជីវធម៌ ឆាប់ក្រោកពីព្រលឹម ទោះមានការរវល់ក្តី គ្មានក្តី ត្រូវតែក្រោកឱ្យទៀងទាត់ពេលវេលា ដើម្បី

ឱ្យស្រួលក្នុងការប្រស្រ័យទាក់ទងគ្នា កុំឱ្យគេពិបាកចាំ កុំឱ្យខាតពេលវេលា ។ លុះក្រោកហើយកុំអង្គុយសំកុក ត្រូវរៀបចំទីដំណេកឱ្យស្អាត កុំក្រោកតែខ្លួនចោលមុងកន្ទេលរោតាត់រោយដូចដំណេកសត្វ នឹងរៀបចំបោសច្រាសផ្ទះសំបែង កុំប្រកាន់ខ្លួនជាអ្វីៗ ព្រោះក្នុងគ្រួសារមួយៗ មានតែមាតាបិតានិងកូនចៅប៉ុណ្ណោះ យើងជាកូនចៅ ត្រូវតែធ្វើជំនួសលោកទាំងអស់ ព្រោះលោកចិញ្ចឹមយើងធំហើយ, បើគ្រួសារយើងមានអ្នកបំរើក៏គួរតែជួយធ្វើគ្នាខ្លះ ចំពោះកិច្ចការដែលគួរធ្វើ មិនត្រូវដេកចាំតែប្រើគ្រប់មួយរយជំពូកនោះទេ ព្រោះអ្នកបំរើក៏ជាមនុស្សជាតិដែរ ។

កាលបើរៀបចំស្អាតបាតហើយ ត្រូវងូតទឹកដុះលាងខ្លួនប្រាណ ស្លៀកពាក់ស្អិតស្អាងឱ្យសមរម្យតាមក្បួនអនាម័យ បើមិនទាន់ដល់ពេលទៅរៀន ទៅធ្វើការ ឬពេលស្រស់ស្រូបចំណីអាហារទេ ត្រូវទន្ទេញមេរៀន ឬមើលសារពត៌មាន ទស្សនាវដ្ដីជាដើម ។ ពេលព្រឹកព្រហាមនេះហើយ ដែលសតិស្មារតី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

កំពុងមានកំឡាំង ព្រោះទើបនឹងសម្រាកហើយ អាចចងចាំអ្វីៗ បានដោយងាយ, បើយើងបណ្ដោយឱ្យការងោកងុយ វាទំពារស៊ីពេលវេលាដ៏មានតម្លៃនេះអស់ទៅ ការខាតបង់ ក្នុងដំណើរជីវិតយើងរឹតតែមានច្រើនឡើង ។

ការក្រោកពីព្រលឹមនេះ មិនមែនល្អវិសេស តែក្នុងសម័យព្រេងនាយ ឬល្អចំពោះតែកសិករកម្មករនោះទេ គឺល្អគ្រប់ឋានៈមនុស្សលោកទាំងអស់, ក្នុងសម័យបរមាណូនេះ ឬហួសសម័យនេះទៅទៀត ក៏នៅតែល្អ រឹតតែល្អឡើង ព្រោះពិភពលោកយើងកាន់តែចង្អៀត អ្នកវិទ្យាសាស្ត្រកំពុងបង្កើតចំណេះវិជ្ជាកាន់តែច្រើន មនុស្សលោកក៏ត្រូវតែរកពេលវេលា ឱ្យកាន់តែច្រើនដែរ ទើបបានរៀនសូត្រ មើលស្ដាប់ ចេះដឹងទាន់ចំណេះវិជ្ជានោះៗ, បើយើងជាអ្នកដេកនិយម មុខជារស់នៅក្រៅសម័យមិនខាន ។

ពេលដើរ ឈរ អង្គុយ ក៏មាតាបិតាលោកប្រដៅឱ្យមានសុជីវធម៌ដែរ គឺដើរឱ្យមានពេលកំណត់ ទៅណាមកណាត្រូវ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ប្រាប់មាតាបិតា ឬអ្នកអាណាព្យាបាល ឬក៏ស្វាមីភរិយាខ្លួនកុំដើរឥតដំណឹង ដើរហួសពេលវេលា ដើរប្រកបដោយអបាយមុខ ។ បើឈរមើលអ្វីៗ ត្រូវឈរឱ្យមានសុជីវធម៌ កុំឈរប្រជែងប្រជាំងបាំងមុខចាស់ទុំនិងស្ត្រីភេទ គួរលៃលកឱ្យមនុស្សចាស់នឹងស្ត្រីមានឱកាសឈរបានស្រួលផង ។ ឯការអង្គុយក៏ដូចគ្នា បើយើងប្រស្រ័យទាក់ទងនិងគេ ត្រូវគិតឱ្យសព្វគ្រប់ កុំនៅអង្គុយនិយាយផ្តេសផ្តាសគ្មានចប់ អង្គុយសំកុកហួសពេលវេលានាំឱ្យរំខានដល់អ្នកដែលខ្លួនប្រស្រ័យជាមួយ ត្រូវស្គាល់ពេលគេដេកពេលគេបរិភោគចំណីអាហារ ឬពេលគេមានការចាំបាច់ ទើបឈ្មោះថាអង្គុយមានសុជីវធម៌ ។

ព្រះរស់គឺមាតាបិតា លោកប្រៀនប្រដៅអប់រំមនុស្សលោកជាបុត្រធីតាគ្រប់វិស័យទាំងអស់ មិនអាចនាំមកនិយាយរាយរាប់ឱ្យបានសព្វគ្រប់ក្នុងពេលនេះទេ, បើរួមឱ្យខ្លីមកលោកប្រដៅបុត្រធីតាឱ្យស្គាល់សិទ្ធិករណីយកិច្ចរបស់ខ្លួន និងរបស់អ្នកដទៃ, ឱ្យលះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

អំពើអាក្រក់ សាងអំពើល្អ ។

អាស្រ័យហេតុនេះហើយ ទើបមានអង្គការជាច្រើនក្នុងលោក មានមុខក្រសួងផ្សេងៗ គ្នា លៃទៅតាមកាលៈទេសៈ ក្រៅពីក្រសួងសុខាភិបាល និងសិក្សាធិការ ដែលបាននិយាយខាងដើម នៅមានក្រសួងយុត្តិធម៌, មហាផ្ទៃ, ហិរញ្ញវត្ថុ, សេដ្ឋកិច្ច, ការបរទេស, ការពារប្រទេស, សាធារណការ និងក្រសួងធម្មការទៀត ។ ក្នុងក្រសួងនិមួយៗ មានចែកច្រើនផ្នែកទៅទៀតតាមសម័យនិយម ។ ទាំងអស់នេះកើតមកពីព្រហ្មវិហារធម៌របស់ព្រះរស់, ដូច្នេះអង្គការនានា និងមុខក្រសួងទាំងឡាយក្នុងលោក គឺជាស្នាដៃរបស់ព្រះរស់បានបង្កើតឡើង ដើម្បីអប់រំសាងមនុស្សលោក ហើយនៅប្រទេសមួយៗ ព្រះរស់នាំគ្នាជ្រើសរើសរកមហាបុរស ដែលបរិបូណ៌ដោយគុណសម្បត្តិសមត្ថភាព ទេពកោសល្យ អភិសេកជាព្រះមហាក្សត្រ តាំងជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ប្រមុខរដ្ឋ ជាប្រធានាធបតី ឬជានាយករដ្ឋ ដើម្បីគ្រប់គ្រងត្រួតបរិហារនូវអង្គការនោះៗ ឱ្យបានលទ្ធផលល្អដល់មនុស្សលោក ។

ដូចនៅប្រទេសកម្ពុជាយើងក្នុងសតវត្សរ៍ទី២០ នៃគ.ស.នេះ ព្រះរស់ទាំងប្រទេស បានលើកសម្តេចព្រះនរោត្តម ដែលជាប់ព្រះសន្តតិវង្ស ពីព្រះមហាក្សត្រាធិរាជ សម័យអង្គរ ជាព្រះប្រមុខរដ្ឋ គោរពបូជាដម្កល់ទុកព្រះអង្គ ជាព្រះអាទិទេពរបស់ខ្លួន ដោយកោតស្ញប់ស្ញែងប្រាជ្ញាបារមីព្រះអង្គ ដែលបានដោះប្រទេសកម្ពុជា ឱ្យរួចពីទាសភាពបរទេស ដោយសន្តិវិធី ហើយជប់ប្រទេសកម្ពុជា ឱ្យកើតជាអរិយប្រទេសគំរូទាន់សម័យមួយនៅអាស៊ីទ្វីប មានកិត្តិសព្ទប្រកបដោយគតិបណ្ឌិត ផ្សាយទូទៅពេញពិភពលោក ។ ឯពួកសត្រូវបរទេសទាំងឡាយ ដែលធ្លាប់តែតាមផ្ចាញ់ប្រទេសកម្ពុជា ដូចមារាធិរាជនោះ ព្រះអង្គទ្រង់ផ្ចាញ់តែដោយព្រះប្រីជាញាណ មិនបាច់ប្រើអាវុធ ឱ្យចាញ់គ្រប់វិស័យ ដូចជាសត្វអំពិលអំពែកចាញ់ពន្លឺព្រះអាទិត្យ ក្នុងសុរិយកាល ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ការសង្គ្រោះបុត្រធីតាឱ្យមានគូរស្រករ

បន្ទាប់ពីបានអប់រំបុត្រធីតាឱ្យមានចំណេះវិជ្ជា កើតសតិបញ្ញាស្គាល់ខុសត្រូវ ចេះធ្វើការចិញ្ចឹមជីវិតមក លោកបានសង្គ្រោះឱ្យមានស្វាមីភរិយា តាមគន្លងប្រពៃណីលោកនិយមទៀត ។

មុននឹងរៀបចំបុត្រធីតា ឱ្យមានស្វាមីភរិយា មាតាបិតាទំពិនិត្យជ្រើសរើសសព្វយ៉ាង លៃថ្លឹងឱ្យមានតុល្យភាពស្មើគ្នា ឬប្រហាក់ប្រហែលគ្នា គឺជ្រើសរើសតាំងពីវង្សត្រកូល, ទ្រព្យសម្បត្តិ, ចំណេះវិជ្ជា, ចរិយាមារយាទ និងរូបសម្បត្តិរហូតដល់ថ្ងៃ - ខែ - ឆ្នាំ ដើម្បីឱ្យកូនទាំងពីរបានសុខចំរើនក្នុងដំណើរជីវិត ។

ការជ្រើសរើសលៃថ្លឹងនេះ លោកចំណាយពេលវេលាជាច្រើន ដើម្បីសាកសួរប្រឹក្សាជាមួយក្រុមញាតិ និងចាស់ព្រឹទ្ធាចារ្យ ទាល់តែមានយោបល់ភាគច្រើនទៅខាងណា ទើបសំរេចទៅខាងនោះ, ជាពិសេស លោកតែងសាកសួរស្ទង់ចិត្តបុត្រធីតាជាមុន ។

ទោះបីលោកទំពិនិត្យពិច័យ យ៉ាងនេះក៏ដោយ គង់តែមាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ឧបស័គ្គខ្លះ នាំឱ្យលោកអាម៉ាស់មុខ ខ្មាស់ញាតិសន្តាន កើតទុក្ខក្រៀមក្រំ ។ ឧបស័គ្គនោះច្រើនមកអំពីបុត្រធីតា ដែលគ្មានការស្មោះត្រង់ ស្វាមីភ័ក្តិចំពោះលោក ដែលជាព្រះបង្កើតក្បាលខ្លួន គឺបុត្រធីតានោះ បានលួចលាក់ស្នេហា ប្តេជ្ញាស៊ូស្លាប់រស់ជាមួយអ្នកដទៃរួចស្រេចទៅហើយ ដល់បិតាមាតាសួរចិត្តនឹងរកគូស្រករឱ្យ រឹតតែកុហកភរភូត បោកបញ្ឆោតលោកថែមទៀត ខ្លះថា "ខ្ញុំមិនទាន់ចង់បានស្វាមីភរិយាទេ!" ខ្លះថា "ខ្ញុំស្អប់មិនចូលចិត្តអ្នកនោះ នាង៍នោះទេ!" ខ្លះទៀតនៅស្ងៀមធ្មឹងដូចរូបតុក្កតា មិនព្រមប្រាប់ការពិត ដល់លោកឱ្យទាល់តែសោះ, លុះរៀបអាពាហ៍ពិពាហ៍ហើយ ឬកំពុងរៀប ឬក៏មិនទាន់ដល់ពេលរៀបផង ស្រាប់តែលួចរត់ ទៅតាមគូស្នេហាលួចលាក់របស់ខ្លួននោះបាត់ទៅ ។

បុត្តធីតាដែលប្រព្រឹត្តដូច្នេះ ជាអ្នកអកតញ្ញូធំណាស់ ធ្វើឱ្យលោកកើតទុក្ខ បំបាក់មុខលោក ឱ្យខ្មាស់គេពាសពេញស្រុក ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ដើម្បីដោះស្រាយបញ្ហានេះឱ្យបានងាយ ហើយទាន់សម័យផង អ្នកនាងជាបុត្តធីតាទាំងឡាយ ត្រូវសង្កត់ចំណុចធ្ងន់មួយទៅក្នុងគំនិតថា "ក្នុងលោកមានតែមាតាបិតាអ្នកបង្កើតខ្លួនយើងទេ ដែលជាព្រះរស់អាចផ្តល់សុខចំរើន ហើយមិនប្រកាន់កំហុសគ្រប់យ៉ាងទាំងអស់ចំពោះយើង ទោះបីលោកខឹងដល់វាយដេរទៅ ក៏លោកហៅមកវិញ" ។

កាលបើអ្នកនាង កំណត់ទុកក្នុងចិត្តមាំដូច្នេះហើយ មុននឹងផ្តក់ស្នេហាទៅលើរូបណា ត្រូវត្រិះរិះពិចារណាដោយប្រាជ្ញារបស់ខ្លួនជ្រើសរើសគូស្នេហាឱ្យហ្មត់ចត់សិន ព្រោះមនុស្សលោកដែលខំសិក្សាវិជ្ជាគ្រប់យ៉ាងតាំងពីតូចមក មិនមែនយកប្រាជ្ញាទៅទុកធ្វើជ្អកទេ ប្រាជ្ញានេះហើយសំរាប់រចនាខ្លួន ឱ្យបានរុងរឿង ឱ្យបានគាប់ចិត្តមាតាបិតាញាតិសន្តាន និងមហាជនទូទៅ ។

បើយើងមិន ចេះជ្រើសរើសស្នេហា ឱ្យសមឋានៈខ្លួនទេ យើងនឹងអន់ជាងសត្វតិរច្ឆានទៅទៀត, សូម្បីសត្វកុកនឹងក្អែក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

*ដែលមានលក្ខណៈដូចគ្នា គ្រាន់តែប្លែកសម្បុរប៉ុណ្ណោះ ក៏វាមិនខ្វីស្នេហាគ្នាផង ។*

*ដូច្នេះអ្នកនាង ត្រូវតែគិតពិចារណាលៃថ្លឹងចិត្តខ្លួន និងចិត្តមាតាបិតាដោយខ្លួនឯង ឱ្យស្រេចជាមុនសិន កុំចេះតែធ្វេចភ្នែកបោះទម្លាក់ស្នេហាព្រាវៗ ទៅនោះឡើយ ។ គឺគិតលៃថ្លឹងថា "អ្នកនេះ នាងនេះ សមឋានៈ[១] នឹងអញឬទេ? មានវង្សត្រកូល, ចំណេះវិជ្ជា, ចរិយាមារយាទ និងពណ៌សម្បុរ ល្មមមាតាបិតាញាតិសន្តានអញរាប់អានកើតឬទេ?" បើយ៉ាងហោចណាស់ក្នុង ១០ ភាគ ក៏ឱ្យបានពាក់កណ្តាលដែរ ។*

---

១-ពាក្យដែលបុគ្គលខ្លះនិយាយថា "សេចក្តីស្នេហាគ្មានព្រំដែន, គ្មានរើសឋានៈបុគ្គល" នោះជាពាក្យទាល់ប្រក ជាពាក្យភាន់ប្រឡំទេ ។ ឯចិត្តដែលស្នេហានោះ វាគ្មានព្រំដែន គ្មានឋានៈពិតមែន ព្រោះជាអរូប បេះតែស្នេហាក្នុងចិត្តម្នាក់ឯងទៅចុះ, ប៉ុន្តែកុំបញ្ចេញឱ្យប្រាកដ បំពោះបុគ្គលណាមួយ ព្រោះរូបបុគ្គលសុទ្ធមានឋានៈ មានព្រំដែនយ៉ាងធំពីធម្មជាតិមក តែស្នេហារំលោភឱ្យខុសឋានៈ ធ្លាយព្រំដែនហើយ ត្រូវលោកជិនត្មះតិះដៀលមិនខាន ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

កាលបើល្មមភាគ សមចិត្តគ្នាទៅវិញទៅមកហើយ ទើបគួរផ្ដក់ស្នេហាគ្នាបាន ហើយអ្នកនាងទាំងពីរ ត្រូវជំរាបមាតាបិតារៀងៗ ខ្លួនភ្លាមតាមការពិត រាយរាប់ហេតុផល ឱ្យលោកបានជ្រាបគ្រប់ចំណុច មិនត្រូវខ្មាស់អៀនលោក ដែលជាព្រះបង្កើតខ្លួនទេ គួរតែខ្មាស់អៀនគូស្នេហាអ្នកនាង ដែលជាអ្នកដទៃនោះវិញ បើអ្នកដទៃគ្មានខ្មាស់អៀន ហ៊ានស្នេហាគ្នាហើយ តើទៅខ្មាស់អៀនអ្វីមាតាបិតាយើង ។ បើអ្នកនាង ជំរាបលោកឱ្យជ្រាបសព្វគ្រប់សមហេតុផលហើយ លោកមុខតែទទួលស្គាល់ហើយឧបត្ថម្ភឱ្យបានសំរេចជាគូស្វាមីភរិយា ដោយរីករាយជាមិនខានប្រសិនបើមាតាបិតានោះ ជាអ្នកសម័យនិយមផង លោកនឹងអនុញ្ញាតឱ្យអ្នកនាងទៅមករាប់រកគ្នា បណ្ដើរគ្នាលេងបានដោយសេរី មុនពេលរៀបអាពាហ៍ពិពាហ៍ថែមទៀត, តែអ្នកនាងទាំងពីរ ត្រូវរក្សាលក្ខណៈស្នេហាសម័យនិយម ឱ្យហ្មត់ចត់ល្អគឺរក្សាព្រហ្មចារីឱ្យបរិសុទ្ធ ដរាបដល់រៀបអាពាហ៍ពិពាហ៍ហើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ម្យ៉ាងទៀត, បើអ្នកនាង គ្មានសមត្ថភាព នឹងរើសរកគូស្វាមីភរិយាខ្លួនឯង ឱ្យបានគាប់ចិត្តមាតាបិតាទេ កុំស្នេហាផ្តេស ផ្តាស លួចលាក់នឹងមាតាបិតា ដែលហៅថាស្នេហាព្រៃផ្សៃ ឬស្នេហាបាតផ្សារនោះឱ្យសោះ ត្រូវរក្សាព្រហ្មចារីឱ្យបរិសុទ្ធ ចាំមាតាបិតារើសរកគូស្វាមីភរិយាឱ្យ ទើបគាប់ប្រសើរមិនខូចប្រពៃណី សមគួរតាមបុរាណនិយម ។

ការរៀបចំឱ្យកូនមានស្វាមីភរិយានេះ មាតាបិតាបារម្ភច្រើនយ៉ាងណាស់ ជាពិសេសក្រែងកូនមិនបានសុខសាន្តជាមួយគ្នាដរាបយាវជីវ៍ ទើបលោកខំរំលឹកទូន្មានកូន អប់រំកូន តាំងពីនៅលីវឱ្យរៀនច្បាប់ស្រី ច្បាប់ប្រុស តាមបុរាណនិយម និងច្បាប់សុជីវធម៌ក្នុងគ្រួសារ តាមសម័យនិយមទៀត ។

ឯច្បាប់ទាំងអស់នោះ មានចំណុចសំខាន់តែម្យ៉ាង គឺអប់រំស្វាមីភរិយាឱ្យមានសេចក្តីសន្តោស ចេះគោរពស្តាប់គ្នា អត់ឱនគ្នាទៅវិញទៅមក កុំឱ្យឈ្លោះទាស់គ្នា ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មូលហេតុដែលនាំឱ្យឈ្លោះទាស់គ្នា រវាងស្វាមីភរិយា បើតាមការពិសោធន៍តាំងពីព្រេងនាយមក ច្រើនបណ្តាលកើតពីភរិយាដែលខ្វះលក្ខណៈជាស្ត្រីមេផ្ទះ ។

ឯលក្ខណៈធំបំផុតរបស់ស្ត្រីមេផ្ទះ គឺសេចក្តីអត់ធន់ ។ ព្រោះធម្មជាតិបានបង្កើតស្ត្រីភេទមក ប្រកបដោយធាតុទន់ខ្សោយ ហើយសុភាពរាបសា មានរូបរាងអវយវៈ ទន់ភ្លន់ ស្លូតបូត សមរម្យជាជម្រកដ៏ត្រជាក់ត្រជុំ របស់ជនក្នុងគ្រួសារ នឹងជាឱសថ ឬជាសាស្ត្រាចារ្យប្រចាំគ្រួសារ សំរាប់អប់រំ បន្ទោបង់នូវកំហុស និងសេចក្តីក្តៅក្រហាយទុក្ខព្រួយរបស់ស្វាមី និងបុត្រធីតា ទើបមាននាមដ៏ឧត្តមថា “មេផ្ទះ” គឺជាមេជម្រក សម្រាប់ស្វាមីបុត្រធីតាជ្រកនៅបានសុខសាន្ត ។

ហេតុនេះ ស្ត្រីមេផ្ទះទាំងឡាយ ត្រូវមានសេចក្តីអត់ធន់ជាចាំបាច់ ដើម្បីរក្សាភាពធម្មជាតិរបស់ខ្លួន ឱ្យមានប្រក្រតីរាបសារីករាយល្អជានិច្ច លះបង់នូវសេចក្តីក្រេវក្រោធ ប្រចំណ្ឌ ប្រមាថ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

មើលងាយ យកឈ្នះពីស្វាមីរបស់ខ្លួន ដែលជាឧបស័គ្គចំពោះធម្មជាតិខ្លួននោះចេញ ។

ភាពល្អរីករាយ ដែលប្រកបដោយសេចក្តីអត់ធន់នេះហើយ ជាអាវុធរបស់ភរិយា គឺជាព្រនង់ទិព្វយ៉ាងធំ សំរាប់សំពងកំទេចចោលនូវអំពើអាក្រក់របស់ស្វាមី ឱ្យអន្តរធានបាត់បង់ទៅដោយស្វ័យប្រវត្តិ ។ ទោះស្វាមីនោះជាមនុស្សពាល មាតាបិតាគ្រូអាចារ្យប្រដៅមិនបានតាំងពីកំណើតមក ក៏ត្រូវតែបាក់បបខ្លបខ្លាចលះបង់អំពើរអាក្រក់ចោលខានមិនបាន, បើជាអ្នកខិលខូចខ្លាំងដល់ពេលប្រែចិត្តគំនិតល្អវិញ ច្រើនតែបន្ទន់ខ្លួនសម្រក់ទឹកភ្នែកថ្លែងកំហុសខ្លួនចំពោះមុខភរិយាទៀត ដោយឥទ្ធិពលព្រនង់ទិព្វនេះឯង ។ ប៉ុន្តែមានបុរសអស់សាច់ យ៉ាងគម្រក់ខ្លះ ដែលព្រនង់ទិព្វនេះ កែមិនឡើងទាល់តែសោះ គឺមនុស្សខូចអាវ៉ាសែមិនចិញ្ចឹមប្រពន្ធកូន ប្រព្រឹត្តអបាយមុខ ឆបោកលួចទ្រព្យសម្បត្តិប្រពន្ធកូនទៅបំផ្លាញ ក្បត់គ្រួសារឯង ស្ត្រីជាភរិយាគប្បី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

លែងចោលឱ្យស្រឡះពីខ្លួន, ព្រោះការលះលែងបុរសធុននេះ ដូចជាគេបន្ទោបង់លាមកចោល ទៅក្នុងបង្គន់ដូច្នោះដែ ។

ស្ត្រីមេផ្ទះ ដែលចេះអត់ធន់មានសេចក្ដីសន្ដោស មិនចង់បានឈ្នះពីស្វាមី មានចរិយាល្អសមហេតុផលនេះហើយ ហៅថាស្រីមានលក្ខណ៍ គឺស្រីល្អ ។

## សមនិង្ភាសិតបុរាណថា:

“ស្រីល្អច្រើនចាញ់ប្ដី ពាក្យអប្រិយចាញ់អាត្មា”

ស្រីល្អក្នុងនេះមិនមែនល្អរូបទេ គឺល្អចរិយាមារយាទឆ្លាតវៃចេះអត់ធន់ មិនដែលយកឈ្នះប្ដីដោយកំឡាំងបាយ ព្រមចាញ់ដោយរីករាយជានិច្ច ហើយអាចយកជ័យជំនះពីប្ដីបានដោយសន្តិភាព ។

ត្រូវនឹងក្បួនឈ្នះដែលមាននៅក្នុងលោកនិតិថា:

“ឈ្នះអ្នកខ្ពស់ដោយត្រូនបន្ទន់ប្រាណ
ឈ្នះអ្នកក្លាហានដោយទំលាយ
ឈ្នះអ្នកខ្សោយដោយឱ្យសម្ដបាយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ឈ្នះអ្នកស្មើកាយដោយព្យាយាម" ។

ឯបុរសមានភេទខ្ពស់, និងកំឡាំងកាយខ្លាំង ជាងភេទស្ត្រី, ដូច្នេះស្ត្រីជាភរិយា មិនអាចតតាំងយកជ័យជំនះ ពីស្វាមីខ្លួនបាន ដោយកំឡាំងបាយ មានការជេរប្រទេចផ្តាសសា ខ្ញារ ខ្ញាំ ខាំ ក្តិច ប្រច័ណ្ឌ ឡូឡា ស្រែកយំជាដើមនោះ ។ ឯការឃោឃៅកាចសាហាវជាដើមនោះ ជាលក្ខណៈរបស់ស្រីខាតលក្ខណ៍ទេតើ! ។

ធម្មតាស្រីខាតលក្ខណ៍ មានតែការឃោរឃៅកាចសាហាវ ប្រច័ណ្ឌប្តីជាចាំបាច់ មិនសូវគិតគូរពីទ្រព្យសម្បត្តិ មានក្រ ល្អ អាក្រក់ និងធ្វើម្ហូបចំណីទេ មានចិត្តជោគជាំជោរអៀចទៅដោយកាមរាគ មួយថ្ងៃៗរកតែរឿងប្រច័ណ្ឌប្តី បើប្តីទៅណា ដល់ត្រឡប់មកវិញ ក្នុងចិត្តពោរពុះក្រឡេកចុងភ្នែកដើមភ្នែក មើលសង្កេតរូបកាយសំលៀកបំពាក់ប្តី ដើម្បីរកលេសចាប់ពិរុទ្ធចោទប្រកាន់ ប្រច័ណ្ឌបៀតបៀន នាំឱ្យមានរឿងហេតុក្តៅធំក្នុងគ្រួសារ ។ បើមាននរណាមកទាក់ទងនិងប្តីខ្លួន លើកប្តីប្រច័ណ្ឌនិងគេភ្លាម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ហើយដើរនិយាយហែកកេរ្តិ៍សំអុយប្ដី ប្រាប់គេឯងរហូតដល់ខ្ញុំកញ្ចះគេក៏ប្រាប់ដែរ ឱ្យតែធ្លាប់ស្គាល់មុខ ហ៊ាននិយាយមើលងាយប្ដីពេញទីថាៈ អាក្បាលខូច អាឆ្កែ អាក្បាលកញ្ចាស់ គំនិតដូចកូនក្មេង អារន្ទះបាញ់. . . ជាដើម ជក់មាត់ល្អណាស់គ្មានញញើតទេ និយាយមិនចង់ឈប់ ភ្លេចពេលបាយទឹកអស់ ។ មានខ្លះទៀតនិយាយជង់យំជង់ ថ្លង់អាការៈយ៉ាងថោកទាបប្រាប់គេឯងឱ្យជួយឈឺឆ្អាលខ្លួន ។ បើនិយាយទៅ ចំស្រីខាតលក្ខណ៍ ដូចគ្នានោះ ត្រូវដើងគ្នាម៉ាំងតែម្ដង តាំងបើកឆាក បង្ហូរកេរ្តិ៍ប្ដីតែរឿងខ្លួន មួយឈុតទៅមួយឈុតមក ចេះតែជក់មាត់ឡើងៗ កូនយំនៅចំពោះមុខក៏មិនឮដែរ ។

ប៉ុន្តែបើនិយាយទៅចំស្រីមានលក្ខណ៍នោះ ដូចជាអាក្រាតកាយនៅខ្លួនទទេ ឱ្យគេស្គាល់ច្បាស់ថា "មេនេះជាស្រីខាតលក្ខណ៍ទេតើ" ហើយគេអាចស្គាល់ជ្រៅ ដល់ទៅថ្លើមប្រមាត់បេះដូងទៀតថាជាស្រីល្មោភមេថុន ពោពេញទៅដោយសេចក្ដី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ស្រែកឃ្លានអន្ទះសាខ្ទារ ក ទើបចេះតែខំប្រឹងប្រែប្រច័ណ្ឌ ការពារទុក ក្រែងមិនបានឆ្អែតស្កប់ស្កល់ ។ ព្រោះការប្រច័ណ្ឌនេះជានិមិត្តរូប ឬជាឃើហោនៃមហាកាមរាគ មានគោលបំណងបាញ់ផ្គោះទៅរកមេថុនផ្ទាល់ខ្លួនតែម្នាក់ឯង ។

គួរឱ្យអាម៉ាស់មុខណាស់ មិនគួរស្រីខាតលក្ខណ៍ពាក់មុខប្រច័ណ្ឌ ឱយគេស្គាល់ឃើហោអាសគ្រាម អាស្រូវបាភយនេះសោះ, ជាពិសេសគួរខ្មាស់ចំពោះស្វាមីខ្លួន ឬកូនខ្លួនដែលដឹងក្តីហើយ ។

ហេតុដូច្នេះគួរស្ត្រីមេផ្ទះ និងនារីជាអនាគតមេផ្ទះទាំងឡាយ ចៀសវាងនូវតម្រាប់អាក្រក់ របស់ស្រីខាតលក្ខណ៍នេះ ជាដាច់ខាត ព្រោះតម្រាប់ដ៏អាក្រក់នេះ អាចរុញច្រានស្វាមី ឱ្យរឹតតែធ្លាក់ចុះទៅក្នុងអំពើមិនគាប់ចិត្តរបស់ខ្លួនថែមទៀត នាំឱ្យវិនាសអន្តរាយ ក្តៅក្រហាយវេទនាតែខ្លួនឯងទេ, ដូចគេបំពក់ជ្រៀវ ដេញឃ្មុំឱ្យហើរចោលសំបុកដូច្នោះដែរ ។

ឯបុរសក៏ដូចគ្នា ព្រោះមានប្រុសខ្លះ ប្រច័ណ្ឌប្រពន្ធដូច្នេះ

ដែរ, គួរបុរសស្វាមី និងអ្នកកំឡោះជាអនាគតស្វាមីទាំងឡាយ កុំត្រាប់តាមបុរសធុននេះឡើយ ។

ម្យ៉ាងទៀតបុរសជាស្វាមី ដែលមានភេទ និងកំឡាំងកាយ ខ្ពង់ខ្ពស់ខ្លាំងពូកែពីធម្មជាតិមកនោះ ត្រូវកាន់ចរិយាមារយាទឱ្យសមឋានៈខ្លួនជាស្វាមីរបស់គេ កុំអាងកំឡាំងបាយវាយឬកខ្ពស់ទល់មេឃ និងកុំឱ្យទាបពេកស្មើដី ដរាបដល់ភរិយារកគោរពប្រតិបត្តិបំពេញឋានៈ ជាស្រីល្អដងមិនកើត ។ មានបុរសខ្លះបន្ទាបខ្លួនឱ្យទាបថោកហួស ដល់ទៅធ្វើខ្ញុំកញ្ចះបាទជើងភរិយាខ្លួន បណ្តាលឱ្យភរិយាឡើងមានៈ មើលងាយដូចសត្វតិរច្ឆាន ។

ឯចំណុចសំខាន់របស់ស្វាមី ដែលត្រូវប្រព្រឹត្តកាន់ឱ្យមានជានិច្ចនោះ គឺសេចក្តីសន្តោសចំពោះភរិយា, ត្រូវប្រៀបធៀបខ្លួននឹងភរិយាខ្លួនហើយ លៃឱ្យមានតុល្យភាពជានិច្ច កុំអាងតែខ្លួនប្រុស ចេះតែប្រព្រឹត្តរម៉ាំងរម៉ោក ខ្ជោកខ្ជាកតាមអំពើចិត្ត រំលោភចំពោះភរិយានោះឡើយ ។ បើភរិយាជាស្រីខាតលក្ខណ៍ពាលា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

កាចសាហាវ មាតាបិតាប្រដៅមិនបាន ហាមប្រាមមិនឈ្នះ យើងត្រូវអប់រំដោយបទទីពាក្នុងក្បួនលោកនីតិដែលថា "ឈ្នះអ្នកខ្សោយដោយឱ្យបាយសម្ល" ពាក្យថាសម្លបាយគឺឱ្យទូទៅគ្រប់យ៉ាង តាំងពីឱ្យសម្លបាយ សំលៀកបំពាក់ មាសប្រាក់រហូតដល់កិត្តិយស និងសេចក្តីសរសើរជាដើម លៃសម្រួលតាមចរិតមនុស្ស ។ ធម្មតាអ្នកទន់ខ្សោយ ដូចជាស្ត្រីដែលខ្សោយភេទជាដើម តែងចាលចាញ់នូវអំណោយ គឺការឱ្យនេះឯង ។

ប៉ុន្តែមានភរិយាខ្លះ ដែលអាក្រក់ហួសហេតុ ដរាបដល់ជិតក្បត់ជាដើមនោះ សូម្បីឱ្យនគរសោយរាជ្យ ក៏មិនស្កប់ចិត្តដែរ

ដូចសុភាសិតក្នុងលោកនិតិបង្គាប់ថាៈ

"ស្រីណាមានប្រក្រតីពោលវិវាទ
មានប្រមាថពោលនាំពាក្យឫស្យា
ត្រេកបំណាងឱ្យប្រុសគន់អាត្មា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

កិរិយាស្លដាំប្រចាំប្ដី ។
ស៊ីបាយមុនប្ដីនៃអាត្មា
ត្រេចយាត្រាផ្ទះគេពុំជួក្ដី
ស្រីយ៉ាងនេះបុរសក្នុងលោកិយ
ទោះមានកូនមួយរយក្ដីគប្បីលែង" ។

ជាអវសាន អ្នកកំឡោះនិងនាងក្រមុំទាំងឡាយ ជាអនាគតស្វាមីភរិយា ចូរប្រុងប្រយ័ត្នកាយវាចាចិត្ត ក្នុងពេលដែលទើបបានជួបគ្នា ជាស្វាមីភរិយាថ្មីថ្មោង កុំបញ្ចេញអាការៈឡេះឡោះប្រឡូកប្រឡែងគ្នា ដូចសហាយស្មន់នោះឡើយ នាំឱ្យមានការមើលងាយគ្នាទៅវិញទៅមក ខូចកិត្តិយសស្វាមីភរិយា ដែលជាគូរប្រចាំជីវិតរបស់ខ្លួន ត្រូវប្រកាន់ចរិយាមារយាទឱ្យសមឋានៈរៀងខ្លួន ល្មមគោរព ស្ដាប់បង្គាប់ កោតខ្លាច ស្រឡាញ់រាប់អានគ្នាបានអស់មួយជីវិត ។

ព្រះរស់គឺមាតាបិតា កាលបើបានចាត់ចែងរៀបចំបុត្រធីតា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ឱ្យកូនមានគូរស្រករតាមប្រពៃណីនិយម បានសុខសាន្តនឹងគ្នាហើយ លោកសប្បាយចិត្តណាស់ ហាក់ដូចជាបានបំពេញករណីកិច្ច ចំពោះលោកគ្រប់អស់ហើយ តែលោកមិនព្រមលះបង់ ចោលបុត្រធីតាត្រឹមនេះទេ លោកនៅតែគិតគូរ បន់ស្រន់ឱ្យកូន បានសុខចំរើនទៅទៀត ។ លោកបានចែកមត៌កឱ្យហើយខ្លួន លោកនៅតែរ៉ាប់រងបំរើ បំពេញបំបានកូនឥតធុញទ្រាន់ដរាបដល់ បានចៅរិតតែស្រឡាញ់ ថ្នាក់ថ្នមបំរើចៅមួយភាគធំថែមទៀត ។

សមនឹងភាសិតបុរាណថា:

"ស្រឡាញ់កូនមួយតៅ ស្រឡាញ់ចៅមួយថាំង" ។

បើលោកមានជីវិតរស់នៅ ដរាបដល់បាន ចៅទួតចៅលួត រឹតតែស្រឡាញ់ថ្នាក់ថ្នម បំរើច្រើនភាគទៅទៀត ។

នេះជាទឹកហឫទ័យ នៃមាតាបិតា ដែលពោរពេញទៅដោយព្រហ្មវិហារធម៌ ចំពោះបុត្រធីតា យ៉ាងទូលាយគ្មានព្រំដែន ។

ពួកបុត្រធីតា គួរតែស៊ូប្តូរផ្តាច់គ្រប់យ៉ាង ចំពោះមាតាបិតា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ឱ្យលើសលុបជាងជីវិតខ្លួនទៅទៀត ទើបធ្ងន់ធ្ងរ ព្រោះថា៖

តាំងពីចាប់បដិសន្ធិមក មាតាបិតាបានប្រគល់ខ្លួនលោក ធ្វើជាទាសកម្មកររបស់កូនដោយរីករាយ អស់មួយជីវិត ឥតគិតថ្លៃឈ្នួល ខំបំរើយ៉ាងថ្នាក់ថ្នម លើសលុបជាងទាសកម្មករទាំងអស់ក្នុងលោក, បំរើគ្មានឈប់សំរាក គ្មានស្គាល់ថ្ងៃសៅរ៍ អាទិត្យ គ្មានគិតយប់ថ្ងៃ គ្មានច្បាប់ឈប់ថ្ងៃបុណ្យទាន គ្មានកំណត់ខែឆ្នាំរ៉ុត្រែត, បំរើហើយបំរើទៀត បំរើតាំងពីកូនដល់ចៅ ចៅទួត បំរើដល់ចាស់សក់ស្កូវ ខ្នងកោង ជ្រុះធ្មេញអស់ បំរើដល់ស្វិតសាច់ ស្រកឈាម ស្បែកយុរយារ បំរើទាល់តែដល់ស្លាប់, ស្លាប់ទៅកើតជាខ្មោចហើយ នៅតែកូនចៅអុជធៀនធូបសំបូងសង្រ្វែងអន្ទងកោះហៅមកប្រើ ឱ្យជួយរកសុខចំរើនឱ្យទៀត ។

ឱ! អ្នកនាងទាំងឡាយជាកូនប្រុសស្រី ចំជាមានសំណាងមែន ក្នុងលោកនេះ គ្មាននរណាមានសំណាងជាងអ្នកនាង ដែលបានមកកើតក្នុងគ្រួសារមាតាបិតាទេ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ដូច្នេះកូនប្រុសស្រីទាំងឡាយ មិនត្រូវបណ្តោយឱ្យភ្នែកងងឹត ត្រចៀកថ្លង់ មើលលោកមិនឃើញ ស្តាប់ឱវាទលោកមិនឮនោះឡើយ ត្រូវតែគោរពស្តាប់ ដឹងគុណ តបគុណ សងគុណលោក ដរាបមួយជីវិត ។

ឯកិច្ចដែលមាតាបិតាទំនុកបំរុង អប់រំកូនប្រុសស្រី ដូចរាយរាប់មកខាងដើមនេះ បើរួបរួមឱ្យខ្លីយកតែត្រង់ចំណុចសំខាន់ ដែលមានក្នុងទ្រឹស្តីពុទ្ធសាសនា មាន ៥ គឺៈ

១ - ហាមឃាត់កូនមិនឱ្យធ្វើអំពើអាក្រក់,
២ - ដឹកនាំកូនឱ្យធ្វើអំពើល្អ,
៣ - ណែនាំកូនឱ្យរៀនវិជ្ជាសិល្បសាស្ត្រ,
៤ - រៀបចំឱ្យកូនមានស្វាមីភរិយាតាមប្រពៃណី,
៥ - ទំនុកបំរុងចែកកេរ្តិ៍មត៌កផ្តល់ទុនឱ្យកូន ។

( ចប់ការសាងមនុស្សលោក )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីឱ្យផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ភាសិត

ម៉ែឪជាបុគ្គលប្រសើរណាស់ក្នុងលោកិយ
កូនប្រុសស្រីកុំយល់ថាមានគុណតែត្រឹមខ្លួន
ម៉ែឪគឺជាម៉ែឪសកលលោកពេញបំនួន
ទាំងជាម៉ែឪក្បួនច្បាប់វិទ្យាសាស្ត្រទាំងអស់ ។
ព្រោះអ្នកប្រាជ្ញអ្នកមានយសអ្នកមានទ្រព្យគ្រប់ឋានៈ
គ្មាននរណាម្នាក់កើតឯងឥតម៉ែឪសោះ
គ្រប់ជាតិសាសន៍សុទ្ធតែកូនម៉ែកូនឪទាំងអស់
នេះឯងព្រះរស់កូនត្រូវបូជាគុណរាល់ពេល ។

( សុង ស៊ីវ )

WAT KHEMARARATANARAM

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ៥ - មនុស្សលោកត្រូវដឹងគុណព្រះរស់

ការដឹងគុណជាករណីកិច្ចចាំបាច់របស់បុត្រធីតា ឯការមិនដឹងគុណ ក៏ជាអករណីកិច្ច របស់បុត្រធីតាដែរ ។

## ប្រភេទនៃការដឹងគុណនិងការមិនដឹងគុណ

បុត្រធីតាទាំងឡាយ គប្បីសំឡឹងមើល រូបកាយរបស់ខ្លួន ហើយពិចារណារកមូលហេតុ ឱ្យឃើញច្បាស់ខ្លួនឯងថាៈ "សក់, រោម, ក្រចក, មុខ, មាត់, សាច់, ស្បែក និងអវយវៈទាំងអស់របស់អញនេះ កើតពីណា? តើនរណាហ្ន៎! ជាអ្នកបង្កើត ហើយចិញ្ចឹមរក្សា ឱ្យរស់មានជីវិត ក្នុងជីវភាពមនុស្សលោក?" ។ អ្នកនាង ប្រាកដជាដឹងច្បាស់ ដោយខ្លួនឯងថា "ម៉ែឪលោកបង្កើត លោកចិញ្ចឹមរក្សាអញ" កាលបើបានដំណឹងនេះច្បាស់ពីមនោវិញ្ញាណរបស់ខ្លួនហើយ អ្នកនាង ត្រូវតែស្រឡាញ់ម៉ែឪ ដឹងគុណ តបគុណ សងគុណ ចិញ្ចឹមរក្សា គោរពបូជាលោកវិញ ខានមិនបាន ទើបអ្នកនាង បានស្ថិតនៅក្នុងភាពជាមនុស្សលោក ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

បើមិនដូច្នោះទេ អ្នកនោះនឹងអស់សិទ្ធិជាមនុស្ស ដោយស្វ័យប្រវត្តិ ទៅជាសត្វតិរច្ឆានទាំងរស់ ។ ព្រោះសភាពសត្វតិរច្ឆានមានក្តៅធ្វាជាដើម វាមិនស្គាល់មេបា មិនចេះដឹងគុណ តបគុណ សងគុណ គោរពបូជាមេបាវាទេ ដូចធ្លាប់ឃើញប្រត្យក្សស្រាប់ហើយ ។

ការពិចារណាដូច្នេះ ជាឧបាយឱ្យកើតកតញ្ញូកតវេទិតាធម៌, ពួកកតញ្ញូកតវេទីទាំងឡាយ លោករលឹកឃើញឧបការគុណមាតាបិតាគ្រប់ពេលដែលលោកឃើញ សក់, រោម, ក្រចក, ប្រមុះ, មុខ, មាត់, ស្បែក អវយវៈទាំងអស់របស់លោកទើបតម្កល់ទុកឧបការគុណមាតាបិតា ក្នុងហឫទ័យលោក ឱ្យស្ថិតនៅជាប់ជានិច្ចគ្រប់ពេលវេលា ។

ការដឹងគុណ ជាករណីកិច្ចខាងគំនិត ដែលបុត្រធីតាត្រូវពិចារណា នឹកដល់ឧបការគុណមាតាបិតា តាំងពីចាប់បដិសន្ធិ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

មក ឱ្យដឹងច្បាស់សព្វគ្រប់អំពីទុក្ករកិច្ច ដែលលោកទំទ្រាំទ្រពផ្ទៃអស់បិរវេលា១០ខែ នឹងពេលប្រសូតិ ដែលប្រកបដោយទុក្ខវេទនាយ៉ាងខ្លោចផ្សា រហូតដល់ការចិញ្ចឹមបីបាច់រក្សា ដុសលាងមូត្រលាមក បញ្ចុកបាយចំណី បង្ហាត់បង្ហាញឱ្យចេះនិយាយស្ដីស្គាល់ទិសទីខុសត្រូវល្អអាក្រក់ ឱ្យសិក្សាវិជ្ជាសិល្បសាស្ត្ររៀបចំឱ្យមានស្វាមីភរិយា ចែកមត៌កផ្ដល់ទុនឱ្យ ដែលសុទ្ធតែជាទុក្ករកម្ម អ្នកដទៃក្រៅពីមាតាបិតា ធ្វើត្រាប់តាមមិនកើតទាល់តែសោះ ។

ឯការតបគុណ ឬ សងគុណ[១] ជាករណីយកិច្ចខាងកាយវិការ ។ បើបុត្រធីតាបានដឹងគុណមាតាបិតាច្បាស់លាស់ ក្នុងចិត្តហើយ អាចលុតជង្គង់លើកដៃប្រណម្យ ថ្វាយបង្គំបាទាលោកជានិច្ចរាល់ពេលវាលាបាន ហើយរីករាយក្នុងការថែរក្សា គក់

---

១-ការគោរពប្រតិបត្តិបិញ្ចឹម បំរើមាតាបិតាគ្រប់យ៉ាងឈ្មោះថា "តបគុណ" ។ ការដឹកនាំ ឬទំនុកបំរុងមាតាបិតាឱ្យបានស្ថិតនៅក្នុងសទ្ធា, សីល, ចាគៈ, បញ្ញាឈ្មោះថា "សងគុណ" ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ប្រាប់ ជូនបាយទឹកនំចំណី សំលៀកបំពាក់ ប្រាក់កាស ថ្នាំកែរោគ និងជូតទឹកដុសលាងជំរះមន្ទិលកាយ ថ្នាក់ថ្នមពាក្យសំដី ឱនលំទោនគោរពប្រតិបត្តិ ស្តាប់តាមឱវាទ បានគ្រប់យ៉ាងទាំងអស់ មិនអៀនខ្មាស់ មិនធុញទ្រាន់ មិនកំណាញ់ ដរាបដល់លោកមរណកាល រៀបចាត់ចែងពិធីឈាបនកិច្ច លើកសពសំស្ការ ធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសផលជូនទៅលោកទៀត តាមប្រពៃណីនិយម ។

បើគ្មានការដឹងគុណឱ្យប្រាកដក្នុងគំនិតទេ កូនប្រុសស្រីមិនអាចលុតជង្គង់លើកដៃប្រណម្យ ថ្វាយបង្គំមាតាបិតាបានឡើយ, ជង្គង់បុត្រធីតានោះ វារឹងហាក់ដូចជាមានសរសៃដែកចាក់បេតុងភ្ជាប់ឆ្អឹង បត់មិនរួចទាល់តែសោះ, ឯដៃទាំងគូរក៏ធ្ងន់រាប់ពាន់តោន មិនអាចលើកប្រណម្យថ្វាយបង្គំមាតាបិតាបានទេ ។ ចំណែកបាយទឹកនំចំណី សំលៀកបំពាក់ ថ្នាំកែរោគ ប្រាក់កាសទៀត ទោះបីបុត្រធីតានោះ ជាសេដ្ឋីគហបតីក៏ដោយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ហាក់ដូចជាក្រខ្សត់ណាស់ មិនអាចលៃលកជូនគាត់បានទេ ចេះតែស្តាយគ្រប់ពេលវេលា ។

បើអ្នកដទៃ ក្រៅពីមាតាបិតាខ្លួនវិញ ជផ្គង់បុត្រធីតានោះ ទន់ណាស់ ហាក់ដូចជាគ្មានសរសៃសោះ គ្រាន់តែឃើញមុខគេ វាទន់លុតជផ្គង់ភ្លាមដោយស្វ័យប្រវត្តិ, ឯដៃទាំងគូរក៏ស្រាលស្រួលជាងប៉ុយគទៅទៀត លើកប្រណម្យគោរពគេភ្លាម ហើយរីករាយថែមទៀត នឹកពេញចិត្តថាអញចេះគួរសមណាស់ ។

សមនឹងសុភាសិតថា:

"ម៉ែឪមានគុណណាស់ មិនសំពះខ្មាស់អៀនដៃ
ឯអ្នកក្រៅដទៃ វិស័យសោះសំពះបាន" ។

ឯបាយទឹកនំចំណី សំលៀកបំពាក់ ថ្នាំកែរោគ ប្រាក់កាសជាដើមទៀត បើអ្នកដទៃវិញ ទុកជាខ្លួនក្រខ្សត់ក៏ដោយ ស៊ូរកខ្ចីបុលគេទៅទំនុកបំរុងយកមុខមាត់ គ្មានស្តាយទេ ហើយនឹកថាបានបុណ្យណាស់ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ជាពិសេសទៅទៀត ចំពោះគូរស្នេហាសហាយស្មន់របស់ខ្លួននោះ វារឹតតែណាស់ទៅទៀត ខំផ្ចិតផ្ចង់គ្រប់វិស័យទាំងអស់ ថ្នាក់ថ្នមតាំងពីពាក្យសំដី របូតចេញពីមាត់មួយម៉ាត់ៗមក ឮតែ "ប្អូនបណ្តូលចិត្ត បងកំពូលជីវិត ប្អូនល្អណាស់ ដូចបុប្ផា ឬព្រះចន្ទពេញវង់ បងដូចភមរជាតិ" សុទ្ធតែជាពាក្យប្រកបដោយវប្បធម៌ជ្រៅជ្រះណាស់ ។

បើនិយាយចំពោះមាតាបិតាវិញ សុទ្ធតែជាពាក្យសំឡុតគំរោះគំរើយចេញមកឮតែ "ម៉ែឯង, ឪឯង, ម៉ាក់ឯង, ប៉ាឯង, ដូនចាស់ឯង តាចាស់ឯង, យាយបាឯង អ៊ុងយ៉ាឯង, ចាស់ហើយគ្មានសណ្តាប់ជាចាស់ ស្អប់ណាស់ ខ្ពើមណាស់ ឃើញមុខនាំឱ្យតែក្តៅ, មានខ្លះដល់ទៅជេរប្រមាថថា មេកញ្ចាស់ អាកញ្ចាស់ជាដើមថែមទៀត ។

ចំណែកខាងកាយវិការវិញ បើចំពោះគូរស្នេហាសហាយស្មន់នោះ មានខ្លះដល់ទៅលុតជង្គង់ សំពះថ្វាយបង្គំសុំស្នេហាគ្នា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ថ្នាក់ថ្នមគក់ច្របាច់ គ្មានចេះរួយដៃទេ ។

មាស ប្រាក់ ពេជ្រវិញចេះតែមាន ចង់បានអ្វីសុទ្ធតែឱ្យលើស បើគ្មានហ៊ានប្រព្រឹត្តចោរកម្ម ស៊ីសំណូកបោកគេឯងឱ្យខាងតែបានបំពេញចិត្តគួរស្នេហា ។ មានខ្លះទៀតហ៊ានលួចទ្រព្យរបស់ម៉ែឪ យកផ្ទះស្រែចម្ការ គោក្របីដីភូមិ ទៅលក់បញ្ចាំឱ្យគេ ហើយនាំគេមកដេញម៉ែឪខ្លួន ឱ្យចុះចេញពីផ្ទះភូមិឋាន ទៅជ្រកក្នុងខ្ទមជរា ឬសំយាបផ្ទះអ្នកដទៃ ។ បើអ្នកមានទ្រព្យសម្បត្តិ យសស័ក្តិវិញ បញ្ចិះគួរស្នេហាសហាយស្មន់សុទ្ធតែឡានថ្មី ទិញឬជួលផ្ទះល្អៗ ឱ្យនៅ ចាយលុយដូចក្រដាសកាសែត គឺមានសទ្ធាជ្រះថ្លាដឹងគុណព្រះស្នេហាមុតមាំណាស់អស់ពីថ្លើមប្រមាត់ ។ បើចំពោះព្រះរស់ គឺមាតាបិតាខ្លួនវិញ តាមមានតាមបាន មិនសូវជាគិតគួរទេ ចេះតែស្រវាំងភ្នែក មើលលោកមិនសូវឃើញសោះ ទាល់តែដល់លោកស្លាប់ទើបនឹកឃើញអញ្ជើញភ្ញៀវមកពេញផ្ទះ ដើម្បីកិត្តិយសខ្លួន កុំឱ្យគេនិន្ទាផង យកចំណេញពីបុណ្យសពម៉ែឪ ធ្វើអ្នកមានផង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ឱ! មាតាបិតាអើយ ចំជាមានគុណប្រយោជន៍ចំពោះបុត្រធីតាមែន ស្លាប់កើតជាខ្មោចហើយ នៅតែផ្តល់កិត្តិយសកិត្តិស័ព្ទឱ្យកូន, មានសពម៉ែឪខ្លះឱ្យកូនបានចំណេញលុយចាយទៀត ។

ប៉ុន្តែមានកូនអកុសលខ្លះ មិនរវល់គិតពីកិត្តិយស មិនកិត្តិយសនោះទេ ឱ្យម៉ែឪស្លាប់ដូចមនុស្សអនាថាគ្មានកូនចៅ ។

ម្យ៉ាងទៀតមានកូនខ្លះ គិតគួរនឹកឃើញម៉ែឪ តែពេលរស់នៅ ដល់លោកស្លាប់ យកទៅកប់ចោលដូចខ្មោចឆ្កែឆ្មា មិនដែលទៅអើតមើលផ្នូរ ឬ ធាតុចេតិយទេ ហាក់ដូចជាផ្នូរ ឬធាតុចេតិយនោះ នៅឆ្ងាយដល់ដើរមេឃទៅមិនដល់សោះ ឯទក្ខិណានុប្បទានក៏មិនដែលធ្វើជូនលោកដែរ ។ សមនិងភាសិតពិសេសមួយរបស់សហជីវិន យូរ - អ៊ុន ដែលមាននៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំទី ២២ លេខ ៣ គ.ស. ១៩៥០ ថា:

"ដំបូលផ្ទះឆ្ងាយជាងដំបូ
គូថភរិយាជិតជាងផ្នូម្ដាយឪពុក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

ដូចរៀបរាប់មកនេះ សុទ្ធតែជាការពិត ធ្លាប់មាននៅក្នុងលោកនេះ បើមិនច្រើនក៏តិចពុំបាន ។

ម្យ៉ាងវិញទៀត កូនប្រុសស្រីទាំងឡាយ ច្រើនគិតគូរទំនុកបំរុង ថែរក្សា ផ្គត់ផ្គង់តែស្វាមីភរិយា នឹងបុត្រធីតាខ្លួន, ឯមាតាបិតា មិនសូវរវល់ទេ បើលោកមានទ្រព្យសម្បត្តិ មាសពេជ្រជាដើមនោះ ទើបខំយកចិត្តទុកដាក់បំរើអបដើង ដើម្បីទាក់យកសម្បត្តិ លុះបានដូចបំណងហើយ ចេះតែណាយចិត្តភ្លេចមួយថ្ងៃបន្តិចៗ យូរៗទៅលះបង់លោកចោលដូចគោចាស់ គ្មានគិតសោះ ឱ្យរស់នៅត្រដាបត្រដួសរហូតដល់ស្លាប់ ។

សមនឹងភាសិតបូរាណថាៈ

"ម្តាយគិតកូនដូចច្រវាប្រដេញ
កូនគិតម្តាយវិញដូចព្រះបៃក្រោយ" ។

មានកូនចង្រៃខ្លះទៀត ប្រណែនដណ្តើមសម្បត្តិគ្នាថា "គេបានច្រើន អញបានតិច គេបានសុទ្ធតែរបស់ល្អ អញបានសុទ្ធ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

តែរបស់អាក្រក់ឡាក់សង" ក៏តាំងដើរនិយាយកើត្ត សំអុយឈ្មោះម៉ែឪខ្លួនប្រាប់អ្នកដទៃ ហើយប្រចាំគ្នា មិនទំនុកបំរុងចិញ្ចឹមរក្សាលោកទេ, ម្នាក់ថា ឱ្យគាត់ផ្ញើរជីវិតនឹងកូនសំឡាញ់គាត់ចុះ ម្នាក់ថា អញមិនគោតចិញ្ចឹមគាត់តែម្នាក់ឯងទេ ម៉ែឪទាំងអស់គ្នា មានម៉ែឪតែអញអី! ទ្រព្យសម្បត្តិគាត់ចែកទាំងអស់គ្នា ។ ប្រចាំចុះប្រចាំឡើង លះបង់ម៉ែឪចោលឱ្យវេទនាអនាថា ។

ដូច្នេះមាតាបិតាទាំងឡាយ ឬអ្នកនាងជាអនាគតមាតាបិតា បើមានទ្រព្យសម្បត្តិ គួរកុំចែកឱ្យកូនអស់ ត្រូវលៃលកទុកសំរាប់ខ្លួនមួយចំណែក ល្មមចិញ្ចឹមជីវិតបានដល់ពេលស្លាប់ ដើម្បីការពារខ្លួន បើកូនវាមិនចិញ្ចឹម កុំឱ្យវេទនាខ្លួនពេក ។

មានកូនខ្លះទៀត កាលមាតាបិតារស់នៅ មិនសូវអើពើទំនុកបំរុងគោរពបូជាទេ ស្រាប់តែលោកឈឺខ្លាំងលេបបាយលេបទឹកមិនរួចហើយ ទើបនាំគ្នាចំណាយទ្រព្យ ទិញម្ហូបនំចំណីទាំងជាសទាំងស្ងួត យកទៅបង្ខំឱ្យលោកពិសារ តើពិសារឯណាបាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

បើបំពង់កវាដេកទៅហើយ កាលដែលបំពង់កនៅឈរនោះ មិនគិតទេ ។ ដល់លោកមរណៈកាលទៅ ក៏តាំងយំសោកបោកខ្លួនប្រាណ ទួញរាយរាប់សរសើរគុណ ខំធ្វើបុណ្យទាន រៀបសំណែនព្រឹកល្ងាច យំហៅម៉ែឪឱ្យមកសេពសោយ តើលោកសេពសោយឯណាបាន បើគ្រាន់តែពេលឈឺខ្លាំង លោកពិសារមិនបានទៅហើយ ។

ធ្វើដូច្នេះក៏មិនគួរដែរ ធ្លាក់ចុះទៅក្នុងតម្រាបុរាណថា៖
"អណ្តើកនៅជើងមិនយក ចាំរកត្អែកោះ"
ឬថា! "កិច្ចប៉ុនភ្នំមិនគិត ទៅគិតគ្រំកំបែកមាត់" ។

ព្រោះម៉ែឪដែលចែកឋានទៅហើយនោះ ដូចបោះម្ជុលទៅក្នុងសមុទ្រមិនដឹងជានៅឯណា មិនងាយបានទទួលផលដែលកូនឧទ្ទិសជូនទៅនោះទេ ។ តែទោះបីយ៉ាងណាក៏ដោយ កាលបើមាតាបិតាមរណៈកាលទៅហើយ កូនត្រូវតែធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនខានពុំបាន, បើលោកពុំបានទទួលទេ ក៏បានបុណ្យ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ខ្លួនឯងដែរ ឯលោកជន ក៏មិនត្អះតិះដៀលផង ។

មានកូនខ្លះទៀត ដឹងគុណមាតាបិតាដែរ តែទុកលោកជាមនុស្សស្មើៗ នឹងខ្លួន ពេលបាយទឹកដេកនៅជាដើម មិនសូវគិតគួរទេ តាមតែលោកបរិភោគ រៀបដំណេក បោកគក់ដេរប៉ះសំពត់អាវខ្លួនឯង, បើមានម្ហូបចំណីល្អៗ វិសេសវិសាលគិតតែផ្ចិតផ្ចង់ យកទៅធ្វើបុណ្យបូជាព្រះឯវត្តនោះវិញ បើមានសេសសល់ពីលោកឆាន់ ទើបហៅមាតាបិតាបរិភោគ ជាមួយខ្លួននឹងកូនចៅខ្លួន ។

ការធ្វើដូច្នេះក៏មិនគួរទៀត ធ្លាក់ក្នុងតម្រាបុរាណថា:
"បោះសន្ទូចរំលងភ្នំ"
ឬថា: "ជ្រះផោប៉ុនគល់ មិនយល់ប៉ុនសក់" ។

ព្រោះមាតាបិតាជាព្រះផ្ទាល់ខ្លួន លោករស់នៅជ្រះផោនឹងមុខ ដែលហៅថាព្រះរស់, កូនប្រុសស្រីត្រូវតែគោរពបូជាលោកដូចព្រះឯវត្តដែរ គឺគួរតែរៀបចំបាយទឹកម្ហូបចំណីដោយឡែក ជូន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

លោកមុន ទើបយកមួយចំណែកទៀត ទៅធ្វើបុណ្យព្រះឯវត្ត ។

សមនិងភាសិតរបស់សហជីវិន ជុំ- មួង ថា:

"ព្រះស្ថិតនៅឯគេហស្ថាន
គួរថ្វាយទានមុនព្រះឯវត្ត" ។

មួយបទទៀតថា:

"ម៉ែឪនៅផ្ទះ លោកទុកជាព្រះ ដូចព្រះឯវត្ត
សំពត់អាហារ កូនត្រូវផ្គង់ផ្គត់ កុំឱ្យលោកអត់
បានបុណ្យដូចគ្នា" ។

ហេតុដូច្នេះ កូនប្រុសស្រីទាំងឡាយ គួរតែប្រតិបត្តិតាមភាសិតនេះ ទើបសមហេតុសមផលល្អ បរិបូណ៌ដោយសុខចំរើន **សមតាមគតិបណ្ឌិត, សូម្បីតែព្រះពុទ្ធជាម្ចាស់ ក៏ព្រះអង្គអនុញ្ញាតឱ្យភិក្ខុសង្ឃ ដែលបិណ្ឌបាតបានចង្ហាន់មក យកទៅជូនមាតាបិតាក្រខ្សត់បរិភោគមុនដែរ បើអស់ទៅរកបិណ្ឌទៀត យកមកឆាន់ជាក្រោយ ។**

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

ការនិយាយរៀបរាប់មកនេះ ដើម្បីបញ្ជាក់ឱ្យឃើញច្បាស់នូវចរិយារបស់បុគ្គលទាំងពីរប្រភេទ គឺកតញ្ញូនិងអកតញ្ញូ ហើយសូមឱ្យអ្នកនាង ជាបុត្រធីតាទាំងឡាយ ស្ថិតនៅតែក្នុងឋានៈជាកតញ្ញូដឹងគុណមាតាបិតាជានិច្ចនិរន្តរ៍ គប្បីក្រាបសំពះ ថ្វាយបង្គំទំនុកបំរុងលោក ដោយបាយទឹកនំចំណីភេសជ្ជៈផ្សេងៗ គ្រឿងស្លៀកពាក់ ទីដេកស្នាក់អាស្រ័យ នឹងថែរក្សាមើលជម្ងឺឈឺចាប់ដោយថ្នាំកែរោគគ្រប់យ៉ាង ហើយប្រោះព្រំមាតាបិតា ដោយគ្រឿងក្រអូបផ្សេងៗ ការពារកុំឱ្យធុំក្លិនអសោច៌ បំរើទឹកក្តៅត្រជាក់គក់ច្របាច់នួតសរសៃ ឱ្យខ្យល់ដើរស្រួលជាដើម និងស្អិតស្អាងលាបប្រេងម្សៅ ដើម្បីជាសុកដល់មាតាបិតាតាមក្បួនអនាម័យ ។

កាលបើកូនប្រុសស្រី បានគោរពប្រតិបត្តិបំរើមាតាបិតាដ៏ល្អប្រកបដោយធម៌ហើយ ពួកទេវតាទាំងឡាយ តែងជួយថែរក្សាឱ្យពរជ័យ ផ្តល់សុខចំរើនរាល់អហោរាត្រ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

កិច្ចគោរពប្រតិបត្តិមាតាបិតា របស់កតញ្ញូកតវេទីនោះ មានច្រើនប្រការណាស់ បើរួមឱ្យខ្លីយកត្រឹមតែចំណុចសំខាន់ ដែលមានក្នុងទ្រឹស្តីពុទ្ធសាសនា មាន ៥ គឺៈ

១- កូនប្រុសស្រី គប្បីចិញ្ចឹមមាតាបិតា,

២- -ដ- គប្បីធ្វើការជូនមាតាបិតា,

៣- -ដ- គប្បីរក្សាវង្សត្រកូលឱ្យស្ថិតស្ថេរ,

៤- -ដ- គប្បីរក្សាមត៌កឱ្យគង់វង់,

៥- -ដ- គប្បីធ្វើទក្ខិណានុប្បទាន តាមកាលសម័យ ឧទ្ទិសផលជូនមាតាបិតា ដែលធ្វើមរណៈកាលហើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ភាសិត

រូបកាយសាច់ឈាមកូនប្រុសស្រី
គឺជាសាក្សីនៃម៉ែឪ
ដែលលោកខិតខំបំរើថៃ
ធ្វើយឥតមានល្ហែជាច្រើនឆ្នាំ
ទម្រាំបានធំកើតជាមនុស្ស
ហេតុនេះកូនប្រុសស្រីចូរចាំ
គុណលោកកុំភ្លេចបុរាណផ្តាំ
ថាបើកូនចាំគុណលោកជួយ ។
( សុន - ស៊ីវ )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

សមនឹងពុទ្ធភាសិតថា:
"ព្រេះកើតពីដែក តែងស៊ីដែកនោះវិញ" ។

ភាសិតបុរាណថា:
"កាំបិតចិតដងឯង"
ឬថា "ដើងធ្លើយត្បិតដង កូនសោតរែងធ្គងព្រោះម្តាយឪពុក ។

ឯលទ្ធផលនៃការដើងគុណក៏ដូចគ្នាដែរ គឺបើមេគ្រួសារនោះ កតញ្ញូ គោរពបូជា ក្រាបសំពះថ្វាយបង្គំ ចិញ្ចឹមរក្សា ផ្គត់ផ្គង់បាយទឹកនំចំណី ទីស្នាក់អាស្រ័យនៅ និងរក្សាថ្នាក់ថ្នមមាតាបិតា ក្នុងពេលលោកមានរោគាពាធម្តងៗ, ប្រើតែពាក្យសំដីសុភាព ឱនលំទោន មិនតប ត ក្នុងពេលលោកស្តីបន្ទោស ខំប្រតិបត្តិ ឱ្យមាតាបិតាសប្បាយចិត្តរាល់ពេលវេលា ។ ដល់មានកូនមក ពួកកូននោះ វាយកតម្រាប់តាមម៉ែឪទាំងអស់ ព្រោះវាធ្លាប់ឃើញច្បាស់នឹងភ្នែកតាំងពីកើតមក ម្លោះហើយកូននោះជាកតញ្ញូកតវេទីពីកំណើត មិនលំបាកប្រៀនប្រដៅទេ វាមានចិត្ត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សារី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រឹន ចន្ធី

ល្អដូចទេវតា ខំរក្សាគោរពបូជាម៉ែឪមិនឱ្យខ្វះកន្លះចិត្ត ចង់បានអីបានភ្លាមដូចជាសោយសម្បត្តិទិព្វ ។ នេះហើយជាបុណ្យជាស្ថានសួគ៌ក្នុងលោកិយដែលជាលទ្ធផលកើតពីការដឹងគុណមាតាបិតា ។

ឯលទ្ធផលក្រៅពីនេះ មានច្រើនប្រការទៀតដូចធ្លាប់ជ្រាបខ្លះមកហើយ ។

ជាពិសេស ឥទ្ធិពលនៃការដឹងគុណមាតាបិតានេះស័ក្តិសិទ្ធិណាស់សូម្បីប្រាថ្នាជាព្រះពុទ្ធ ក៏បានសម្រេចដូចបំណង ដោយសារកតញ្ញូកតវេទីតាធម៌នេះឯង ។

ដូច្នេះអ្នកនាងជាបុត្រធីតាទាំងឡាយ ត្រូវតែដឹងគុណ តបគុណ សងគុណ គោរពបូជាព្រះរស់ គឺមាតាបិតាខានពុំបាន ។

( បប់ដោយសង្ខេប )

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ជួយកែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

# ភាសិត

អ្នកដែលមិនដឹងគុណមិនតបគុណ
ដូចដុំថ្មធ្ងន់ធ្លាក់ក្នុងទន្លេ
មិនដែលអណ្តែតលើទឹកបានទេ
ទេព្តាតែងជេរផ្តន្ទាជានិច្ច
ឯអ្នកដឹងគុណហើយធ្វើតបគុណ
តែងតែប្រកបមិនដែលលង់លិច
ទោះបីទាល់ក្រខ្សត់ខ្សោយដូចម្តេច
ទេព្តាមិនភ្លេចជួយថែរក្សា ។

(សុធ - ស៊ីវ)

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ អ្នកស្រី រស់ សាវី
ផ្ទៀងផ្ទាត់កែសម្រួលទម្រង់ និង អក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី